EDU/MAN - 259

រាជរដ្ឋាភិបាលកម្ពុជា
គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់

សៀវភៅណែនាំស្តីពី
ជនជាតិដើមភាគតិច និងការចូលរួម
ក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

ខែកញ្ញា ឆ្នាំ២០០៣

មាតិការអត្ថបទ

ផ្នែកទី១ : ក្របខ័ណ្ឌច្បាប់

១.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១

១.២. ប្រកាសអន្តរក្រសួង លេខ០៩៨ប្រក ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ១

១.៣. គោលនយោបាយទូទៅ សំរាប់ការអភិវឌ្ឍន៍ប្រជាជនតំបន់ខ្ពង់រាប ១

ផ្នែកទី២ : ប្រជាជនតំបន់ខ្ពង់រាប នៅប្រទេសកម្ពុជា

២.១. ប្រវត្តិសង្ខេប ៣

២.២. លក្ខណៈប្រជាជនតំបន់ខ្ពង់រាប ៦

ផ្នែកទី៣ : ការចូលរួមរបស់ជនជាតិដើមភាគតិច នៅក្នុងដំណើរការអភិវឌ្ឍន៍ឃុំ

៣.១. ការរៀបចំបញ្ជីឈ្មោះភូមិ ឃុំ ដែលមានជនជាតិដើមភាគតិចរស់នៅ ៨

៣.២. កំណត់ប្រជុំជាមួយប្រជាជនតំបន់ខ្ពង់រាប ៩

៣.៣. ដំណើរការកសាងផែនការអភិវឌ្ឍន៍ នៅបណ្តាឃុំដែលមានជនជាតិដើមភាគតិច

- ៣.៣.១. ជំហានទី១ ១០
- ៣.៣.២. ជំហានទី២ ១០
- ៣.៣.៣. ជំហានទី៣ ១២
- ៣.៣.៤. ជំហានទី៤ ១៧
- ៣.៣.៥. ជំហានទី៥ ១៨
- ៣.៣.៦. ជំហានទី៧ ១៩
- ៣.៣.៧. ជំហានទី៩ ១៩
- ៣.៣.៨. ជំហានទី១១ ១៩

ផ្នែកទី៤ : ការតាមដាន និងវាយតំលៃ ២០

ឧបសម្ព័ន្ធ : គំរោងវិនិយោគជនបទ និងអតិថិជនកិច្ចមូលដ្ឋាន ២៣

ផ្នែកទី១ : ក្របខ័ណ្ឌច្បាប់

១.១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

☞ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា មាត្រា៣១ (វាក្យខ័ណ្ឌទី១) មានខ្លឹមសារថា : "**ប្រជាពលរដ្ឋខ្មែរគ្រប់រូប** មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សំបុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ" ។

☞ នៅក្នុងការពិភាក្សាច្បាប់រដ្ឋធម្មនុញ្ញ សភាជាតិបានជជែកដេញដោលក្នុងការកំណត់និយមន័យនៃពាក្យ "**ពលរដ្ឋខ្មែរ**" ។ ពលរដ្ឋខ្មែររួមមានទាំង **ជនជាតិដើមភាគតិច**កម្ពុជាដូចជាប្រជាជនតំបន់ខ្ពង់រាបដែលគេហៅថាខ្មែរលើ ។

១.២. ប្រកាសអន្តរក្រសួង លេខ០៥៨ប្រក ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់

☞ ប្រកាសអន្តរក្រសួងលេខ០៥៨ ប្រក ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០០២ ស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ប្រការ៨ ចែងថា គ្រប់អង្គការសង្គមស៊ីវិល អាចចូលរួមក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគរបស់ឃុំ សង្កាត់ ហើយនឹងទទួលខុសត្រូវ :

- ចូលរួមជាតំណាងអោយផលប្រយោជន៍របស់សហគមន៍មូលដ្ឋាន និងអ្នកពាក់ព័ន្ធណាមួយជាក់លាក់ ដូចជាស្ត្រី យុវជន ជនក្រីក្រ **ជនជាតិដើមភាគតិច** ។ល។
- ចូលរួមចំណែកផ្តល់ចំណេះដឹង និងគំនិតផ្សេងៗ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ ។

១.៣. គោលនយោបាយទូទៅ សំរាប់ការអភិវឌ្ឍន៍ប្រជាជនតំបន់ខ្ពង់រាប

☞ នៅឆ្នាំ១៩៩៧ គណៈកម្មការអន្តរក្រសួងសំរាប់ការអភិវឌ្ឍន៍ប្រជាជនតំបន់ខ្ពង់រាបបានរៀបចំសេចក្តីព្រាង "**គោលនយោបាយទូទៅសំរាប់ការអភិវឌ្ឍន៍ប្រជាជនតំបន់ខ្ពង់រាប**" ។ សេចក្តីព្រាងនេះ បានបញ្ចប់ដោយឆ្លងកាត់ដំណើរការពិគ្រោះយោបល់មួយដ៏វែងឆ្ងាយ ជាមួយនឹងក្រុមនានានៅមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនានា និងរដ្ឋាភិបាល ។ សេចក្តីព្រាងគោលនយោបាយនេះ រដ្ឋាភិបាល មិនទាន់បានទទួលយកជាផ្លូវការនៅឡើយទេ ។

☞ គោលនយោបាយនេះ នឹងផ្តល់ការការពារមួយចំនួនដល់ប្រជាជនតំបន់ខ្ពង់រាប ដែលភាគច្រើនជាបញ្ហាទាក់ទងទៅនឹងសិទ្ធិកាន់កាប់ដីធ្លី និងការប្រើប្រាស់ធនធាន ។

☞ នៅក្នុងគោលនយោបាយទូទៅនេះ បានចែងនូវសារៈសំខាន់ជាពិសេស :

- រដ្ឋាភិបាល ត្រូវបង្កើនការយល់ដឹង និងគោរពវប្បធម៌ចំរុះ ព្រមទាំងធានាថា ប្រជាជនតំបន់ខ្ពង់រាប អាចគោរពប្រតិបត្តិនូវវប្បធម៌របស់ខ្លួនផ្ទាល់ ។
- ប្រជាជនតំបន់ខ្ពង់រាប មានសិទ្ធិពេញលេញ ក្នុងការកំណត់អាទិភាព និងអនុវត្តការគ្រប់គ្រងទៅលើការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងវប្បធម៌ របស់ពួកគេ ។
- សហគមន៍ប្រជាជនតំបន់ខ្ពង់រាប ត្រូវបានផ្តល់ឱកាសអោយមានការចូលរួម និងទទួលខុសត្រូវ នៅគ្រប់ការសំរេចចិត្តអំពីគំរោងហេដ្ឋារចនាសម្ព័ន្ធទាំងអស់ ដែលអាចមានផលប៉ះពាល់ដល់ពួកគេ ។ គំរោងអភិវឌ្ឍន៍ណាមួយ អាចអនុវត្តទៅបាន លុះត្រាតែសហគមន៍ និងបុគ្គលដែលទទួលរងនូវផលប៉ះពាល់ បានផ្តល់ការយល់ព្រម បន្ទាប់ពីពួកគេបានទទួលពត៌មានពេញលេញ (ជាភាសាដែលពួកគេអាចយល់យ៉ាងច្បាស់លាស់) អំពីគំរោង និងរាល់ផលវិបាកដែលកើតចេញមកពីការអនុវត្តគំរោងមកលើពួកគេ និងបរិស្ថានធម្មជាតិ ។

☞ ផែនការអភិវឌ្ឍន៍ប្រជាជនតំបន់ខ្ពង់រាបរបស់គំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន **(RILGP)** មានភ្ជាប់មកជាមួយឯកសារមេរៀននេះ នៅឧបសម្ព័ន្ធ ។ ឯកសារនៅឧបសម្ព័ន្ធនេះ ត្រូវបានប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការអនុវត្តគំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ។

ផ្នែកទី២ : ប្រជាជនតំបន់ខ្ពង់រាប នៅប្រទេសកម្ពុជា

២.១. ប្រវត្តិសង្ខេប

អត្ថបទបន្ទាប់ទៅទៀតនេះបានដកស្រង់ចេញពីឯកសារ :

១). ប្រជាជនជនជាតិដើមភាគតិច ឬជនជាតិភាគតិច និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ី ខែមិថុនា ឆ្នាំ២០០២ ។

២). ការសិក្សាអំពីជនជាតិដើមភាគតិចតំបន់ខ្ពង់រាប ដោយធនាគារពិភពលោក ខែតុលា ឆ្នាំ២០០២ (គំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋានក្នុងប្រទេសកម្ពុជា) ។

☞ ប្រទេសកម្ពុជាជាសង្គមមានជាតិពន្ធចំរុះ (ជាតិសាសន៍ចំរុះ) ដែលក្នុងនោះជនជាតិខ្មែរមានភាគច្រើន ។ ជាតិពន្ធទាំងនោះរាប់បញ្ចូលទាំង វៀតណាម ចាម ចិន និង**ជនជាតិដើមភាគតិច** ។

☞ **ជនជាតិដើមភាគតិច** (ប្រជាជនតំបន់ខ្ពង់រាប) តាមអត្ថន័យរបស់ពាក្យគឺ សំដៅអ្នកស្រុកចាស់បុរាណជាងគេរស់នៅក្នុងប្រទេស ។ ជំនឿសាសនា និងរបៀបនៃការរស់នៅរបស់ពួកគេរាប់សតវត្សមកហើយនោះ ត្រូវបានគេរកឃើញថាមានជាប់ទាក់ទងទៅនឹងធនធានធម្មជាតិ និងបរិស្ថាន ។

☞ ឆ្លងតាមប្រវត្តិរបស់ពួកគេ ប្រជាជនតំបន់ខ្ពង់រាបបានរក្សាទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងគ្នានឹងគ្នា ដូចប្រជាជនខ្មែរ និងប្រជាជនផ្សេងៗលើទឹកដីវាលរាបដែរ ។

☞ មានភស្តុតាងជាច្រើនអំពីវត្ថុបុរាណ ប្រវត្តិសាស្ត្រ និងរឿងនិទានខ្លីៗ ដើម្បីបញ្ជាក់ថាជនជាតិដើមភាគតិចនៃតំបន់ខ្ពង់រាប ក្នុងខេត្តមួយចំនួន មានជីវិតរស់នៅទីនោះអស់ជាច្រើនសតវត្សមកហើយ ។ អាចនិយាយបានថា អ្វីៗដែលនៅជាប់ជាមួយនឹងទឹកដីពីដូនតានៅតែមានមកទល់សព្វថ្ងៃ ។ ដូចគ្នានេះដែរ ដីនិងព្រៃ ជាប្រពៃណីបានបង្កើតនូវមូលដ្ឋាននៃការចិញ្ចឹមជីវិតរបស់ជនជាតិដើមភាគតិច នៅតំបន់ខ្ពង់រាប ក្នុងនោះរាប់ទាំង **ជីវិតអារក្ស** របស់គេផងដែរ ។ ប្រព័ន្ធជំនឿជាប្រពៃណីត្រូវបានជឿថា អ្វីៗទាំងអស់ មានវិញ្ញាណក្នុងធម្មជាតិ នោះគឺការគោរពលើអារក្សដែលរស់នៅក្នុងបឹង ភ្នំ ដើមឈើ និងវត្ថុធម្មជាតិផ្សេងៗទៀត ។

☞ ដោយសារមិនមានការសិក្សាស្រាវជ្រាវពិស្តារ ទៅលើប្រវត្តិដើមនៃជនជាតិដើមភាគតិចកម្ពុជា អ្វីដែលគេបានស្មានចំពោះប្រវត្តិនៃសហគមន៍ទាំងនោះ គឺផ្អែកតាមការពិចារណាលើភាសា :

- ប្រជាជនជនជាតិដើមភាគតិចនៅកម្ពុជា ភាគច្រើនលើសលុប (រួមទាំងខ្មែរ) និយាយភាសាអំបូរ **ខ្មែរ-មន** នៃគ្រួសារ **អូស្ត្រូ-អាស៊ីអាទិច**
- លើកលែងតែភាសារបស់ជនជាតិចារាយ និងក្រុមជនជាតិចាម (និងក្រុមអ្នកនិយាយភាសា **រដែ** មួយចំនួនតូចនៅមណ្ឌលគីរី) ដែលជាភាសារបស់គ្រួសារ អំបូរ **អូស្ត្រូនេស៊ាន** ។

☞ មានការប៉ាន់ស្មានថា ការផ្លាស់លំនៅរបស់ជនជាតិដើមភាគតិចកម្ពុជា ជាយូរលុងមកហើយ មកពីទិសខាងជើង (ភាគច្រើន) ។ ដោយឡែកការផ្លាស់លំនៅរបស់ជនជាតិចារាយ ទំពួន និងកាចក់ គឺមកពីទិសអាគ្នេយ៍ ។

☞ ការរស់នៅជិតដួនតារបស់ខ្លួន គឺមានសារៈសំខាន់ ។ ក្នុងអំឡុងពេលរបប **ប៉ុល ពត** មានអ្នកភូមិជាច្រើនបានជំលៀសចេញ ឬត្រូវគេបំបែកបំបាក់ ។ មួយចំនួនបានគេចខ្លួនដោយសារសង្គ្រាម ។ បន្ទាប់ពីស្ថានភាពបានស្ងប់បន្តិច ប្រជាជនជាច្រើន ហាក់ដូចជា បានវិលត្រឡប់មកកាន់ភូមិកំណើតរបស់ខ្លួនវិញ ។

☞ **អ្នកភូមិជនជាតិដើមភាគតិចម្នាក់ បានរៀបរាប់ថា :**

"យើងបានរស់នៅទីនេះអស់រយៈពេល១៥ឆ្នាំមកហើយ ។ មុននេះយើងរស់នៅភ្នំថាយុ ជិតព្រំដែនប្រទេសឡាវ ព្រោះពូកយើងចាំបាច់ត្រូវរត់គេចពីសង្គ្រាម យើងរស់នៅទីនោះអស់រយៈពេលពាឆ្នាំ .....។ នេះជាភូមិចាស់របស់យើង យើងមានដីចំការនៅទីនេះ ហើយដួនតារបស់យើង ក៏រស់នៅទីនេះដែរ" ខេត្តរតនគីរី ។

☞ ក្នុងបណ្តាឆ្នាំកន្លងមកនេះ របាយប្រជាជនជនជាតិដើមភាគតិចកម្ពុជា មានការប្រែប្រួលដោយសារសម័យកាលដែលមានការផ្លាស់ប្តូរដ៏ឆាប់រហ័ស ។ ជនជាតិដើមភាគតិចខ្លះ បានទទួលយករបៀបរស់នៅថ្មី ដោយការជ្រើសរើស ឬដោយការបង្ខំ ព្រមពេលជាមួយគ្នានេះ ជនជាតិដើមភាគតិចខ្លះនៅរក្សារបៀបរស់នៅតាមប្រពៃណីដើមរបស់ខ្លួនដែលមានលក្ខណៈខុសពីខ្មែរ ។

☞ ប្រពៃណីសង្គមតំបន់ខ្ពង់រាប មានទំនាក់ទំនងយ៉ាងខ្លាំងទៅនឹងដីធ្លី ។ ភូមិនីមួយៗ មានដី និងព្រៃឈើជាប្រពៃណីរបស់ខ្លួន ដែល :

- មានតំបន់ខ្លះ ប្រើប្រាស់សំរាប់ប្រមូលអនុផលព្រៃឈើ និងបរបាញ់
- តំបន់ខ្លះប្រើប្រាស់សំរាប់ដាំដុះ និង
- តំបន់ខ្លះទៀតសំរាប់គោរពបូជាទុកដូចជា **លំនៅដ្ឋានរបស់អារក្ស**

☞ ការដាំដុះតាមប្រពៃណី គឺការធ្វើកសិកម្មពនេចរ។ នៅក្នុងប្រព័ន្ធកសិកម្មនេះ ចំការនីមួយៗត្រូវបានកសិករដាំដុះរយៈពេល២ ឬពាន្លាំ មុននឹងបោះបង់ឱ្យនៅទំនេរ ដែលអាចអោយព្រៃដុះដាលឡើងវិញ ព្រមពេលជាមួយគ្នានេះ គាត់នឹងផ្លាស់ទីទៅចំការថ្មីដែលស្ថិតនៅក្នុងដីភូមិ ជាប្រពៃណីរបស់គាត់ ។

☞ នៅពេលដែលចំការចាស់ណាមួយ មានជីជាតិគ្រប់គ្រាន់ កសិករនេះអាចនឹងត្រឡប់ទៅដាំដុះនៅទីនោះវិញ ហើយខួបនេះនឹងកើតមានឡើងដដែលៗ ។ ការប្រើប្រាស់ប្រព័ន្ធនេះ ធ្វើអោយព្រៃឈើនៅតំបន់ខ្ពង់រាប អាចនៅសល់យ៉ាងច្រើន និងមានតុល្យភាពជាច្រើនសតវត្ស ។ ទោះបីជាមានទស្សនៈអវិជ្ជមានខ្លះទៅលើប្រព័ន្ធកសិកម្មពនេចរនេះក៏ដោយ ប៉ុន្តែការព្រមព្រៀងជាផ្លូវការបានកំណត់ថា ប្រព័ន្ធនេះមានការវិវឌ្ឍន៍ខ្ពស់ ការដាំដុះមានប្រសិទ្ធភាពនិងមាននិរន្តភាពនៅក្នុងតំបន់ដែលមានដង់ស៊ីតេប្រជាជនទាប។

☞ ដីចំការបន្ទាប់ពីប្រើប្រាស់សំរាប់ការដាំដុះ (ចំការចាស់នេះ នឹងបង្កើតបានជាប្រព័ន្ធបរិស្ថានព្រៃឈើឡើងវិញ) គឺជាប្រភពផ្តល់នូវផលិតផលព្រៃឈើ និងអាហារដែលជាធនធានសំខាន់ទី២ សំរាប់ទ្រទ្រង់ដល់ការរស់នៅរបស់ប្រជាជនតំបន់ខ្ពង់រាប ។

☞ ជាប្រពៃណី ប្រព័ន្ធជំនឿរបស់ប្រជាជនតំបន់ខ្ពង់រាប គឺវិញ្ញាណនៅក្នុងធម្មជាតិដែលនោះ គឺជាការគោរពលំនៅដ្ឋានអារក្ស នៅលើភ្នំ ដើមឈើ ឬតំបន់ធម្មជាតិណាមួយ ។

☞ ការបន់ស្រន់អារក្ស គឺជាការសុំអោយមានការសំរេចអ្វីមួយ ដូចជាការជ្រើសរើសចំការថ្មី ។ ពិធីបន់ស្រន់តែងធ្វើឡើង ដោយមានការចូលរួមពីអ្នកភូមិជប់លៀង ច្រៀងរាំ និងសែនព្រេនសត្វមាន់ ជ្រូក គោ ឬក្របី ។ល។

☞ សំរាប់ប្រជាជនតំបន់ខ្ពង់រាប គេមិនអាចបែងចែកអោយដាច់ស្រឡះរវាងពិភពអរូបីយ៍(អារក្ស) និងរូបីយ៍បានឡើយ ។ ទំនាក់ទំនងរបស់ប្រជាជនតំបន់ខ្ពង់រាប និងពិភពធម្មជាតិ ត្រូវបានកំណត់ដោយទំនាក់ទំនងរបស់ពួកគេទៅនឹងពិភពអារក្សទាំងនោះ (ភ្នំ ព្រៃឈើ ឬតំបន់ធម្មជាតិណាមួយ) ដូច្នេះហើយ បានជាជំនឿសាសនារបស់ពួកគេជាប់ទាក់ទងយ៉ាងជិតស្និទ្ធ ទៅនឹងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព ។

២.២. លក្ខណៈប្រជាជនតំបន់ខ្ពស់រាប

☞ រាជរដ្ឋាភិបាលកម្ពុជា មិនបានរក្សាស្ថិតិជាផ្លូវការដែលទាក់ទងនឹងជនជាតិដើមភាគតិចឡើយ ហើយទិន្នន័យប៉ាន់ប្រមាណ និងភូមិសាស្ត្ររស់នៅរបស់ជនជាតិដើមភាគតិចទាំងនោះ មានតិចតួចបំផុត ។

☞ នៅឆ្នាំ១៩៩២ នាយកដ្ឋានជនជាតិដើមភាគតិច បានចុះបញ្ជីជនជាតិដើមភាគតិចចំនួន៣៥ក្រុម ហើយមានចំនួនសរុប ប្រមាណជា ៤% នៃប្រជាជនកម្ពុជា។ ចំនួនភាគរយនេះ ដូចគ្នានឹងចំនួនភាគរយដែលបានប៉ាន់ប្រមាណ ដោយក្រសួងមហាផ្ទៃ នៅឆ្នាំ១៩៩៥ដែរ ។

☞ ជាទូទៅនៅក្នុងបរិបទនៃប្រទេសកម្ពុជា ជនជាតិវៀតណាម ចិន ចាម និងឡាវ មិនត្រូវបានចាត់ទុកថាជាជនជាតិដើមភាគតិចឡើយ ហើយជនជាតិទាំងនេះ មិនបង្ហាញអោយឃើញថា ជាក្រុមជនជាតិដែលងាយទទួលរងគ្រោះនោះទេ ។

☞ ជាទូទៅ ប្រជាពលរដ្ឋខ្មែរ បានចាត់ទុកក្រុមជនជាតិដើមភាគតិច ថាជា**ខ្មែរលើ** ដែលមានប្រពៃណីវប្បធម៌ និងការប្រកបរបរចិញ្ចឹមជីវិតមានលក្ខណៈខុសប្លែកពីគេ ។ ជាទូទៅក្រុមជនជាតិដើមភាគតិចនេះបង្ហាញអោយឃើញនូវលក្ខណៈងាយនឹងទទួលរងគ្រោះបំផុត :

- ជាប់ទាក់ទងនឹងទឹកដី និងធនធានពីដូនតា
- ពឹងផ្អែកលើផលិតកម្មសំរាប់ផ្គត់ផ្គង់តែជីវភាពប្រចាំថ្ងៃ
- ខ្លួនឯង ឬអ្នកដទៃ ផ្តល់អត្តសញ្ញាណថា ជាក្រុមខុសប្លែកពីគេ
- ប្រើភាសាខុសពីភាសាដែលគេប្រើប្រាស់ភាគច្រើន ឬភាសាផ្លូវការ នៅក្នុងប្រទេស
- ពឹងផ្អែកលើវប្បធម៌ និងសង្គមសេដ្ឋកិច្ចតាមទំនៀមទំលាប់ប្រពៃណី

☞ ទោះបីជាភាគរយរបស់ប្រជាជនតំបន់ខ្ពង់រាប មានចំនួនតិចធៀបនឹងចំនួនប្រជាជនសរុបក៏ដោយ ក៏ប្រជាជនតំបន់ខ្ពង់រាប ត្រូវគេបានប៉ាន់ប្រមាណថា ជាតំណាងភាគច្រើននៃប្រជាជន នៅខេត្តរតនគីរី និងខេត្តមណ្ឌលគីរី ដែលខេត្តទាំងពីរនេះ ស្ថិតនៅភាគឦសាននៃប្រទេសកម្ពុជា ។ ប្រជាជនតំបន់ខ្ពង់រាប មានចំនួនភាគរយតិចតួចបំផុត នៅខេត្តដទៃទៀត ។

☞ នៅឆ្នាំ២០០២ ការសិក្សាស្រាវជ្រាវអំពីជនជាតិដើមភាគតិចតំបន់ខ្ពង់រាប បានធ្វើឡើងដែលជាផ្នែកមួយ នៃ**ការរៀបចំគំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន (RILGP)** ។ ការសិក្សាស្រាវជ្រាវនេះ បានសន្និដ្ឋានថា ប្រជាជនតំបន់ខ្ពង់រាបនៅខេត្តរតនគីរី ក្រចេះ ព្រះវិហារ និងកំពង់ស្ពឺ បានបង្ហាញអំពីលក្ខណៈដាច់ដោយឡែក ដែលចាត់ទុកជាលក្ខណៈរបស់ប្រជាជនតំបន់ខ្ពង់រាប ។ ក្រុមជនជាតិទាំងនេះ (**ទំពួន គួយ ចារាយ ភ្នង ត្រឹង ការ៉ែត ព្រៅ ស្ទៀង លន់ និងក្រុមផ្សេងទៀត**) មានចំនួនសរុបប្រមាណ **១២០.០០០ នាក់** ឬប្រហែលជា ១% នៃប្រជាជនកម្ពុជាសរុប ។

ផ្នែកទី៣ : ការចូលរួមរបស់ជនជាតិដើមភាគតិច នៅក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ

៣.១. ការរៀបចំបញ្ជីឈ្មោះភូមិ ឃុំ ដែលមានជនជាតិដើមភាគតិចរស់នៅ

☞ អ្នកសំរបខេត្ត ស្រុក ត្រូវបំពេញតារាងខាងក្រោម មុននឹងចាប់ផ្តើមជំហានទី១ នៃដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ ចំពោះខេត្តដែលដឹងពីកន្លែងរស់នៅរបស់ប្រជាជនតំបន់ខ្ពង់រាប (ឬជនជាតិដើមភាគតិច) ។

☞ តារាងនេះ ត្រូវរក្សាទុកដោយក្រុមប្រឹក្សាឃុំ ។ តារាងនេះ នឹងអាចជួយក្រុមប្រឹក្សាឃុំ ដើម្បីសំរេចថា តើពួកគេត្រូវការបញ្ចូលសមាជិកបន្ថែមទៅក្នុងគណៈកម្មការកសាងផែនការ និងថវិកា (គ.ផ.ថ) ក្នុងនាមជាតំណាងអោយជនជាតិដើមភាគតិចដែរឬទេ? ។

តារាងជនជាតិដើមភាគតិច នៅខេត្ត.....

ថ្ងៃទី..... ខែ..... ឆ្នាំ២០០...

ស្រុក	ឃុំ	ភូមិ	ជនជាតិ	លេខកូដឃុំ	លេខកូដភូមិ

៣.២. កំណត់ហេតុប្រជុំជាមួយប្រជាជនតំបន់ខ្ពង់រាប

កាលបរិច្ឆេទប្រជុំ :

ទីកន្លែងប្រជុំ :

តំណាងក្រុមជនជាតិដើមភាគតិច :

ឧទាហរណ៍ :

- ជនជាតិ..... ចំនួន.....នាក់ ស្ត្រី.....នាក់
- ជនជាតិ..... ចំនួន.....នាក់ ស្ត្រី.....នាក់
- ជនជាតិ..... ចំនួន.....នាក់ ស្ត្រី.....នាក់
- ..... ។ល។

តើការប្រជុំមានការបកប្រែជាភាសាជនជាតិដើមភាគតិចដែរឬទេ? ដោយនរណា?

ឧទាហរណ៍ : បកប្រែជាភាសា..... ដោយលោក ឬលោកស្រី.....

សេចក្តីសង្ខេបនូវអ្វីដែលបានពិភាក្សា :

ហត្ថលេខារបស់មេឃុំ :----------

កំណត់សំគាល់ :

ពត៌មានទាំងនេះ សំរាប់បញ្ចូលបន្ថែមទៅនឹងកំណត់ហេតុប្រជុំ ដែលឃុំធ្លាប់ធ្វើកន្លងមក ។ នេះមិនមែនជាគំរូកំណត់ហេតុថ្មីដែលត្រូវអនុវត្តចំពោះឃុំដែលមានជនជាតិដើមភាគតិចរស់នៅនោះទេ ។

៣.៣. ដំណើរការកសាងផែនការ នៅបណ្តាឃុំដែលមានជនជាតិដើមភាគតិច

> គ្រប់ការប្រជុំពិភាក្សា និងការផ្សព្វផ្សាយពត៌មានទាំងអស់ដែលមានវត្តមានរបស់ជនជាតិដើមភាគតិច ត្រូវធ្វើការបកប្រែភាសាដែលពួកគាត់អាចយល់បាន ។

៣.៣.១. ជំហានទី១

☞ មេឃុំ ត្រូវធានាថា ការប្រជុំរបស់ គ.ផ.ឃ នៅក្នុងជំហាននេះ មានតំណាងរបស់ជនជាតិដើមភាគតិចចូលរួម ។ បើពុំមានតំណាងរបស់ជនជាតិដើមភាគតិចទេ ការប្រជុំនេះ គួរលើកទៅធ្វើនៅពេលក្រោយ ។

☞ មុននឹងចាប់ផ្តើម អ្នកសំរបសំរួលស្រុក ត្រូវរៀបចំការប្រជុំជាមួយក្រុមប្រឹក្សាឃុំ និង គ.ផ.ឃ ដើម្បីបង្ហាញអំពី "**ជនជាតិដើមភាគតិច និងការចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ**" ។

☞ តំណាងជនជាតិដើមភាគតិច ត្រូវពិនិត្យមើលថា :

- តើផែនទីឃុំ មានបញ្ចូលទីកន្លែងសំខាន់ៗរបស់ខ្លួនដែរឬទេ? ដូចជា ទីកន្លែងគោរពបូជា ទីកន្លែងសំរាប់ជាំដុះ ទីកន្លែងភូមិដ្ឋាន .... ។ល។
- តើបញ្ហា តំរូវការ និងដំណោះស្រាយដែលលើកឡើងជាដំបូងទាំងនេះ មានទាក់ទងទៅនឹងជនជាតិដើមភាគតិចដែរឬទេ ? ។ បើមិនមាន ហើយបើអាចធ្វើទៅបាន តំណាងជនជាតិដើមភាគតិច ត្រូវលើកឡើងអំពីបញ្ហា តំរូវការ និងដំណោះស្រាយរបស់ជនជាតិដើមភាគតិច ។

៣.៣.២. ជំហានទី២

☞ នៅភូមិដែលមានជនជាតិដើមភាគតិចរស់នៅ មុននឹងចាប់ផ្តើមការពិភាក្សា គ.ផ.ឃ ត្រូវបង្ហាញអំពី "ជនជាតិដើមភាគតិច និងការចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ឃុំ" ។ គ.ផ.ឃ ត្រូវប្រាកដថា ក្រុមជនជាតិដើមភាគតិចគ្រប់ប្រភេទ មានវត្តមាននៅក្នុងការប្រជុំនេះ ។

☞ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយចំនួននៃតម្រូវការ ឬដំណោះស្រាយអាទិភាពរបស់ប្រជាជនតំបន់ខ្ពង់រាបដែលបានដកស្រង់ពីការសិក្សារបស់ធនាគារពិភពលោក :

- ការព្យាបាលជំងឺសំខាន់ៗមួយចំនួន ជាពិសេសជំងឺគ្រុនចាញ់ ។
- សេវាកម្មផ្នែកឆ្លប សំរាប់ស្ត្រីមានផ្ទៃពោះ (ទទួលបានពីការសំភាសន៍ក្រុមស្ត្រី) ។
- សេវាកម្មពន្យាកំណើត (ទទួលបានពីការសំភាសន៍ក្រុមស្ត្រី) ។
- សេវាកម្មអប់រំសុខភាព និងសុខភាពរបស់ស្ត្រី (ទទួលបានពីការសំភាសន៍ក្រុមស្ត្រី) ។
- ការអប់រំសុខភាពដល់អ្នកភូមិ ។
- សេវាកម្មពេទ្យសង្គ្រោះបន្ទាន់ ឬមុង ។

- សាលារៀនសំរាប់ក្មេងៗ នៅក្នុងភូមិ ឬជិតៗភូមិ ។
- គ្រូបង្រៀន ។
- សំភារៈសិក្សា ដូចជា សៀវភៅ ប៊ិច និងឧបករណ៍សំរាប់បង្រៀន ។
- ការសិក្សាភាសាខ្មែរ : កែលំអជំនាញក្នុងការនិយាយ និងសរសេរ ដើម្បីអោយទំនាក់ទំនងជាភាសាខ្មែរកាន់តែប្រសើរ
- បណ្តុះបណ្តាលអ្នកដែលអាចរស់នៅ និងបង្រៀន នៅក្នុងភូមិ ដើម្បីអោយក្លាយជាគ្រូបង្រៀន ។
- លើកទឹកចិត្តឪពុកម្តាយ អោយបញ្ជូនកូនទៅសាលារៀន និងអោយយល់ដឹងពីសារៈសំខាន់នៃការសិក្សា ។
- បង្រៀនអក្ខរៈកម្មជាភាសាខ្មែរដល់មនុស្សចាស់ (ទទួលបានពីក្រុមនៅខេត្តរតនគីរី) ។
- ការអប់រំទូទៅដល់ស្ត្រីពេញវ័យ (ទទួលបានពីការសំភាសន៍ក្រុមស្ត្រី) ។
- អណ្តូងស្តុប់ផ្តល់ទឹកស្អាតសំរាប់ហូប និងទឹកសំរាប់ប្រើប្រាស់ក្នុងគ្រួសារ ។
- សាងសង់ផ្លូវថ្មី ។
- ជួសជុលផ្លូវ សាងសង់ និងជួសជុលស្ពាន និងលូ ។
- សំណើផ្សេងៗទៀត រួមមានការសាងសង់អាងស្តុកទឹក និងប្រព័ន្ធស្រោចស្រព ។
- សេវាកម្មផ្សព្វផ្សាយកសិកម្មជាប្រចាំដល់អ្នកភូមិ ។
- សេវាកម្មផ្សព្វផ្សាយកសិកម្ម ដើម្បីជួយកសិករ ក្នុងការបង្កើនផលស្រូវនៅតាមដីទំនាប ។
- ផ្តល់សត្វជាកំលាំងអូសទាញ សំរាប់ការងារដាំដុះ ពិសេសការធ្វើស្រែនៅតាមដីទំនាប ។
- ឧបត្ថម្ភគាំទ្រដល់ការចិញ្ចឹមសត្វស្រុក ពិសេសពូជសត្វដែលល្អ ដូចជាជ្រូក និងមាន់ ទា ។
- សេវាកម្មផ្សព្វផ្សាយពីការចិញ្ចឹម និងព្យាបាលសត្វ រួមទាំងការចាក់វ៉ាក់សាំងសត្វ បណ្តុះបណ្តាលអំពីការថែទាំសត្វ ដើម្បីដោះស្រាយនូវអត្រាសត្វស្លាប់ដែលមានកំរិតខ្ពស់ ។

តារាងជំនួយស្មារតីទី ២

ប្រធានបទដែលបានពិភាក្សា		ដំណោះស្រាយ ដែលបានស្នើឡើងដោយអ្នកភូមិ	អាទិភាព	យោបល់ឯកភាពរបស់ជនជាតិដើមភាគតិច
បញ្ហា	កំរូវការ			
1	2	3	4	5

ការបំពេញកូឡោនទី៥ :

- ប្រសិនបើ ដំណោះស្រាយ មានការឯកភាពពីជនជាតិដើមភាគតិច សូមគូសសញ្ញា " ✓ "
- ប្រសិនបើ ដំណោះស្រាយ មិនមានការឯកភាពពីជនជាតិដើមភាគតិច សូមសរសេរ "មិនឯកភាព"
- ប្រសិនបើ ដំណោះស្រាយ បានលើកឡើងដោយជនជាតិដើមភាគតិច សូមសរសេរ "ជនជាតិដើមភាគតិច"

៣.៣.៣. ជំហានទី៣

☞ បន្ទាប់ពីគណនាមធ្យមភាគនៃអាទិភាពដំណោះស្រាយដែលបានផ្តល់ដោយភូមិនីមួយៗ គ.ផ.ឃ នឹងពិភាក្សាដើម្បីដាក់ពិន្ទុទៅលើភាពចាំបាច់នៃដំណោះស្រាយទាំងអស់ ។ នៅពេលនេះ គ.ផ.ឃ ត្រូវផ្តល់ឱកាសអោយតំណាងជនជាតិដើមភាគតិច ធ្វើការពន្យល់ អំពីសារៈសំខាន់ និងភាពចាំបាច់នៃដំណោះស្រាយរបស់ជនជាតិដើមភាគតិចទាំងនោះ ។

តារាងជំនួយស្មារតីសំរាប់ប្រើក្នុងជំហានទី ៣.១

ល.រ	ដំណោះស្រាយស្នើឡើង	អាទិភាពស្រង់ចេញពីតារាងភូមិ					ពិន្ទុសំរាប់ពិចារណា			អាទិភាពសំរេច
		ក	ខ	គ	ឃ	.....	ទូទាំងឃុំ	ចាំបាច់	ពិន្ទុសរុប	
1	2	3					4	5	6=4+5	7
សេដ្ឋកិច្ច										
១										
២										
សង្គមកិច្ច										
១										
២										
ធនធានធម្មជាតិនិងបរិស្ថាន										
១										
២										
សេវាកម្មរដ្ឋបាលនិងសន្តិសុខ										
១										
២										
យេនឌ័រ										
១										
២										

តារាងជំនួយស្មារតីទី ៣.២

លរ	ដំណោះស្រាយឃុំសង្កាត់	អាទិភាព	ក្នុងគោលបំណង	យោបល់ឯកភាពរបស់ជនជាតិដើមភាគតិច
1	2	3	4	5
ផ្នែកសេដ្ឋកិច្ច				
១				
២				
ផ្នែកសង្គមកិច្ច				
១				
២				
ផ្នែកធនធានធម្មជាតិនិងបរិស្ថាន				
១				
២				
ផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ				
១				
២				
ផ្នែកយេនឌ័រ				
១				
២				

- ប្រសិនបើ អាទិភាព មានការឯកភាពពីជនជាតិដើមភាគតិច សូមគូសសញ្ញា " ✓ "
- ប្រសិនបើ អាទិភាព មិនមានការឯកភាពពីជនជាតិដើមភាគតិច សូមសរសេរយោបល់របស់ពួកគាត់ "ខ្ពស់" ឬ "មធ្យម" ឬ "ទាប"

ការងារបន្ទាប់ពីជំហានទី៣

- ☞ បន្ទាប់ពីបញ្ចប់ជំហានទី៣ (ការបូកសរុប និងចាត់អាទិភាពដំណោះស្រាយ) ត្រូវរៀបចំការប្រជុំភូមិជាមួយជនជាតិដើមភាគតិចម្តងទៀត និងរៀបចំផែនទីនៃការប្រើប្រាស់ធនធានធម្មជាតិ និងទីតាំងគោរពបូជាជាប្រពៃណីរបស់ជនជាតិដើមភាគតិច ។
- ☞ បន្ទាប់មក បញ្ចូលសកម្មភាពនានាដែលបានស្នើឡើង ទៅក្នុងផែនទីនោះផងដែរ ។ ត្រូវធ្វើការពិភាក្សាប្រសិនបើមានផលប៉ះពាល់អវិជ្ជមានណាមួយដល់ជនជាតិដើមភាគតិច ក្នុងការប្រើប្រាស់ធនធានធម្មជាតិដែលបណ្តាលមកពីសកម្មភាពទាំងនោះ ។
- ☞ កត់ត្រានៅក្នុងកំណត់ហេតុ ប្រសិនបើមានបញ្ហាផ្សេងៗ ហើយកំណត់ហេតុទាំងនេះត្រូវផ្ញើទៅក្រុមប្រឹក្សាឃុំ ។
- ☞ ផែនទីដែលមាននៅក្នុងឯកសារពត៌មានស្ថានភាពឃុំ គួរត្រូវបានប្រើប្រាស់សំរាប់ការងារនេះ ។

ផែនទីដែលមាននៅក្នុងឯកសារពត៌មានស្ថានភាពឃុំ



៣.៣.៤. ជំហានទី៤

- ☞ នៅក្នុងជំហានទី៤ គ.ជ.ច នឹងពិភាក្សាគ្នា ដើម្បីរៀបចំទិសដៅ យុទ្ធសាស្ត្រ និងរៀបចំឃ្លាដំណោះស្រាយ អោយទៅជាទំរង់សកម្មភាព ។
- ☞ គ.ជ.ច ត្រូវធានាថា យុទ្ធសាស្ត្រដែលបានរៀបចំ សមស្របទៅនឹងស្ថានភាព និងលក្ខណៈរបស់ជនជាតិដើមភាគតិចផងដែរ ។
- ☞ អ្នកសំរបសំរួលស្រុក ត្រូវធានាថា មិនមានយុទ្ធសាស្ត្រ និងសកម្មភាពណាមួយ នៅក្នុងតារាងជំនួយស្មារតីទី៤ ត្រូវបានជំទាស់ពីជនជាតិដើមភាគតិចនោះទេ ។

តារាងជំនួយស្មារតីសំរាប់ប្រើក្នុងជំហានទី ៤

ទិសដៅ (ផ្នែកសេដ្ឋកិច្ច)	
យុទ្ធសាស្ត្រ	សកម្មភាព
១.	១.១ .....
	១.២. .....
២.	២.១. .....
	២.២. .....
	.....
ទិសដៅ (ផ្នែកសង្គមកិច្ច)	
យុទ្ធសាស្ត្រ	សកម្មភាព
១.	១.១ .....
	១.២. .....
២.	២.១. .....
	២.២. .....
	.....

៣.៣.៥. ជំហានទី៥

តារាងជំនួយស្មារតីទី ៥

លរ	ឈ្មោះគំរោង	គំរោងឆ្នាំមុន	ប្រភេទ	ទីតាំងគំរោង	ចំនួនលទ្ធផល	តំលៃប៉ាន់ស្មាន	អ្នកទទួលផល		អាទិភាព	យោបល់ឯកភាពរបស់ជនជាតិដើមភាគតិច
							ប្រភេទ	ចំនួន		
1	2	3	4	5	6	7	8	9	10	11
ផ្នែកសេដ្ឋកិច្ច										
១										
២										
ផ្នែកសង្គមកិច្ច										
១										
២										
ផ្នែកធនធានធម្មជាតិនិងបរិស្ថាន										
១										
២										
ផ្នែកសេវាកម្មរដ្ឋបាលនិងសន្តិសុខ										
១										
២										
ផ្នែកយេនឌ័រ										
១										
២										

ដូចគ្នានឹងកូឡោនទី៥ នៃតារាងជំនួយស្មារតីទី ៣.២ ។

៣.៣.៦. ជំហានទី៧

☞ គ.ផ.ច នឹងពិភាក្សាគ្នា ដើម្បីស្រង់តំរោងដែលមានអាទិភាពខ្ពស់ (នៅក្នុងតារាងជំនួយស្មារតីទី៥) បញ្ចូលទៅក្នុងតារាងទី៧ ។ ក្នុងករណី តំរោងដែលមានអាទិភាពខ្ពស់របស់ជនជាតិដើមភាគតិច មិនត្រូវបានបញ្ចូលទៅក្នុងតារាងទី៧ តំណាងជនជាតិដើមភាគតិច ត្រូវព្យាយាមស្នើសុំដល់សមាជិក គ.ផ.ច ដាក់បញ្ចូលតំរោងអាទិភាពខ្ពស់របស់ជនជាតិដើមភាគតិច ទៅក្នុងតារាងទី៧ ។

៣.៣.៧. ជំហានទី៩

☞ ជំហានទី៩នេះសំខាន់ណាស់ "ការពិចារណាក្នុងការប្រើប្រាស់ធនធានថវិការបស់ឃុំ សំរាប់អនុវត្តគំរោងវិនិយោគឃុំ" ។ ដូចនេះ តំរូវអោយមានតំណាងជនជាតិដើមភាគតិចចូលរួមក្នុងការពិភាក្សានេះ ដើម្បីធានាថា ការសំរេចប្រើប្រាស់ធនធានថវិកាឃុំ ផ្តល់ផលប្រយោជន៍ដល់ពួកគាត់ ។

៣.៣.៨. ជំហានទី១១

☞ **សកម្មភាព "ខ" : បង្ហាញសេចក្តីព្រាងចំពោះអ្នកភូមិ**

សមាជិក គ.ផ.ច របស់ឃុំដែលមានជនជាតិដើមភាគតិចរស់នៅ ត្រូវរៀបចំការប្រជុំជាមួយជនជាតិដើមភាគតិចទាំងនោះ ដើម្បីផ្សព្វផ្សាយសេចក្តីព្រាងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល និងទទួលអនុសាសន៍ពីក្រុមជនជាតិដើមភាគតិចមកវិញ ។ ត្រូវប្រើប្រាស់ផែនទីដើម្បីជាជំនួយក្នុងការប្រជុំនេះ ។ ក្នុងករណី តំរោងអាទិភាពដែលស្នើឡើងដោយជនជាតិដើមភាគតិច ពុំត្រូវបានបញ្ចូលទៅក្នុងសេចក្តីព្រាងនេះ ត្រូវបញ្ជាក់អំពីមូលហេតុអោយបានច្បាស់លាស់ ។

☞ **សកម្មភាព "ឃ" : ក្រុមប្រឹក្សាឃុំអនុម័ត កម្មវិធីវិនិយោគឃុំ**

ក្នុងករណី តំរោងអាទិភាពដែលស្នើឡើងដោយជនជាតិដើមភាគតិច ត្រូវបានស្នើអោយដកចេញពីកម្មវិធីវិនិយោគឃុំ ក្រុមប្រឹក្សាឃុំ ត្រូវបញ្ជាក់អោយបានច្បាស់លាស់ថា គេត្រូវដោះស្រាយយ៉ាងដូចម្តេចចំពោះបញ្ហានោះនៅលើកក្រោយ ។

ផ្នែកទី៤ : ការតាមដាន និងវាយតំលៃ

សង្ខេបការងារ	អ្នកតាមដាន	មធ្យោបាយ	កន្លែងដែលអាចរកបាន
• ការផ្សព្វផ្សាយពត៌មាន និងការសំរបសំរួល ត្រូវធ្វើជាភាសាជនជាតិដើមភាគតិច ។ • កំណត់ហេតុ ត្រូវបញ្ជាក់អោយបានច្បាស់ បើអ្នកសំរបសំរួល សមាជិកក្រុមប្រឹក្សាឃុំ ឬតំណាងភូមិ ត្រូវបានណែនាំអោយធ្វើការផ្សព្វផ្សាយពត៌មានជាភាសាជនជាតិដើមភាគតិច បន្ទាប់ពីការប្រជុំ ។	ក្រុមប្រឹក្សាឃុំ ឬ គ.ផ.ថ	កំណត់ហេតុដែលបានកត់ត្រានៅកំឡុងពេលប្រជុំ ត្រូវបញ្ជាក់អោយបានច្បាស់ បើមានការបកប្រែភាសានៅពេលប្រជុំនោះ ។	នៅសាលាឃុំ
	អ្នកសំរបសំរួល	អ្នកសំរបសំរួល ពិភាក្សាជាមួយប្រជាជនតំបន់ខ្ពង់រាបបើពួកគាត់ត្រូវបានអញ្ជើញអោយចូលរួមក្នុងការពិភាក្សា និងត្រូវបានជំរាបអំពីសេចក្តីសំរេចចិត្តដែលបានធ្វើក្នុងពេលប្រជុំ ។ ត្រូវអោយមានការពិភាក្សាយ៉ាងហោចណាស់ មួយដងនៅក្នុងវដ្តនៃការកសាងផែនការ ។	នៅការិយាល័យគណៈកម្មាធិការប្រតិបត្តិ ។
អ្នកសំរបសំរួល គប្បីផ្តល់ឱកាសដល់ប្រជាជនតំបន់ខ្ពង់រាប ដើម្បីពិចារណាទៅលើអ្វីដែលនាំអោយមានការផ្លាស់ប្តូរដោយសារសកម្មភាពការអភិវឌ្ឍន៍ ។	ទីប្រឹក្សាពង្រឹងសមត្ថភាពមូលដ្ឋាន ។	សំភាសន៍ប្រជាជនតំបន់ខ្ពង់រាបអំពីគំរោងជាក់លាក់មួយចំនួនដើម្បីកំណត់ថា តើពួកគេបានដឹងឬមិនបានដឹងអំពីសក្តានុពលនៃការផ្លាស់ប្តូរដែលកើតឡើងដោយសារគំរោងអភិវឌ្ឍន៍ទាំងនោះ ។ ត្រូវធ្វើកិច្ចការនេះ នៅពេលបញ្ចប់វដ្តកសាងផែនការ ។	រាយការណ៍ក្នុងរបាយការណ៍ប្រចាំខែរបស់PLG ផ្ញើជូន SFTS ។
ចំពោះភូមិដែលមានជនជាតិដើមភាគតិច ក្រុមប្រឹក្សាឃុំ ត្រូវធានាថា តំណាងជនជាតិដើមភាគតិច មាននៅក្នុង គ.ផ.ថ ។	ក្រុមប្រឹក្សាឃុំ ដោយមានជំនួយពីអ្នកសំរបសំរួល និងមន្ទីរផែនការ	ក្រុមប្រឹក្សាឃុំ រក្សាការកត់ត្រាតំណាងភូមិ និងប្រភេទនៃជនជាតិរបស់គេ ។	នៅសាលាឃុំ

សង្ខេបការងារ	អ្នកតាមដាន	មធ្យោបាយ	កន្លែងដែលអាចរកបាន
ឃុំដែលមានភូមិជនជាតិដើមភាគតិច នីតិវិធីនៃកម្មវិធីសិលា តំរូវអោយមានតំណាងក្រុមជនជាតិដើមភាគតិច ចូលរួមក្នុងដំណើរការនៃការបង្កើតទិសដៅអភិវឌ្ឍន៍ និងយុទ្ធសាស្ត្រនានា ហើយត្រូវបានកត់ត្រាទុកនៅក្នុងកំណត់ហេតុអោយបានត្រឹមត្រូវ ។	ក្រុមប្រឹក្សាឃុំ និងអ្នកសំរបសំរួល	កំណត់ប្រជុំនានា ក្រោយជំហានទី៤	នៅសាលាឃុំ
ឃុំដែលមានភូមិជនជាតិដើមភាគតិច ត្រូវធ្វើការប៉ាន់ប្រមាណថា តើគំរោងផ្តល់ផលប្រយោជន៏ទៅលើតំបន់មួយ ហើយមានផលប៉ះពាល់អវិជ្ជមានទៅដល់ភូមិជិតខាងដែលឬទេ? ជាពិសេសត្រូវកំណត់អោយបានច្បាស់ថា ការគួរផែនទី និងសិទ្ធិកាន់កាប់ដីធ្លី គឺច្បាស់គ្រប់គ្រាន់ដើម្បីការពារប្រជាជនតំបន់ខ្ពង់រាប ពីការហូរចូលមកតាំងទីលំនៅថ្មី ឬការបាត់បង់លទ្ធភាពប្រើប្រាស់ធនធាននានា ។	ក្រុមប្រឹក្សាឃុំ និងអ្នកសំរបសំរួល	កំណត់ហេតុក្រោយជំហានទី៣ ត្រូវកត់ត្រាអំពីការប៉ាន់ប្រមាណទៅលើសកត្តានុពលដែលនាំអោយមានឥទ្ធពលអវិជ្ជមាន ។	នៅសាលាឃុំ
គំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន នឹងមិនផ្តល់មូលនិធិដល់សកម្មភាពណាមួយដែលប៉ះពាល់ដល់ជនជាតិដើមភាគតិច ដោយមិនមានការយល់ព្រមជាមុនរបស់ពួកគាត់ឡើយ ។ ការយល់ព្រមនេះ ត្រូវធ្វើឡើងតាមរយៈការប្រជុំភូមិ ។	ទីប្រឹក្សាពង្រឹងសមត្ថភាពមូលដ្ឋាន ។	ទីប្រឹក្សាពង្រឹងសមត្ថភាពមូលដ្ឋាន ត្រូវសាកសួរអ្នកភូមិ ហើយកត់ត្រាអោយបានច្បាស់ថាតើពួកគេ ត្រូវបាន ឬមិនបានប្រឹក្សាអំពីគំរោងដែលប៉ះពាល់ដល់ខ្លួន ។	របាយការណ៏ក្នុងរបាយការណ៏ប្រចាំខែរបស់PLG ផ្ញើជូន SFTS ។

សង្ខេបការងារ	អ្នកតាមដាន	មធ្យោបាយ	កន្លែងដែលអាចរកបាន
ក្នុងករណីដែលផែនការអភិវឌ្ឍន៍ប្រចាំឆ្នាំរបស់ឃុំ មិនបានឆ្លើយតបទៅនឹងតំរូវការអាទិភាពដែលបានលើកឡើងដោយភូមិជនជាតិដើមភាគតិច ក្រុមប្រឹក្សាឃុំ នឹងប្រើផែនការហិរញ្ញវត្ថុបីឆ្នាំរបស់ខ្លួន ដែលមាននៅក្នុងផែនការប្រាំឆ្នាំ ដើម្បីកំណត់ការប្តេជ្ញាចិត្តរបស់ខ្លួនដូចជានៅពេលណា និងវិសាលភាពត្រីមណាដែលអាទិភាពរបស់ពួកគាត់ត្រូវបានឆ្លើយតប ។	ក្រុមប្រឹក្សាឃុំ និងអ្នកសំរបសំរួល	អ្នកសំរបសំរួល ត្រូវពិនិត្យផ្ទៀងផ្ទាត់ថា ក្រុមប្រឹក្សាឃុំបានកំណត់បញ្ហាជាក់លាក់នេះនៅក្នុងផែនការហិរញ្ញវត្ថុបីឆ្នាំរបស់ខ្លួន ។	នៅសាលាឃុំ

កម្មវិធីសិលា

របស់រាជរដ្ឋាភិបាលកម្ពុជា

គំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន ដែនការអភិវឌ្ឍន៍របស់ប្រជាជនតំបន់ខ្ពង់រាប

គណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសិលា

ថ្ងៃទី១១ ខែមីនា ឆ្នាំ២០០៣

គំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន នៅប្រទេសកម្ពុជា
ផែនការអភិវឌ្ឍន៍របស់ប្រជាជនតំបន់ខ្ពង់រាប

សេចក្តីផ្តើម

១. ធានាគារពិភពលោក កំពុងរៀបចំគំរោងវិនិយោគជនបទ និងអភិបាលកិច្ចមូលដ្ឋាន **(RILGP)** ដើម្បីគាំទ្រដល់ការពង្រីកកម្មវិធីសិលារបស់រាជរដ្ឋាភិបាលកម្ពុជា ។ កម្មវិធីនេះ នឹងដើរទន្ទឹមគ្នាជាមួយនឹងយុទ្ធនាការផ្លូវការដ៏ធំមួយ ដើម្បីជំរុញ និងលើកកំពស់អោយមានការចូលរួមរបស់ថ្នាក់មូលដ្ឋាន ក្នុងការកសាងផែនការអភិវឌ្ឍន៍ តាមបែបវិមជ្ឈការ ។ ផ្នែកសំខាន់ៗមួយនៃកម្មវិធីដែលគាំទ្រដោយគំរោង **RILGP** នេះ ជំរុញអោយមានការចូលរួមរបស់ប្រជាពលរដ្ឋមូលដ្ឋាន ក្នុងការកំណត់ និងចាត់អាទិភាពតំរូវការមូលដ្ឋាន ។ គំរោងនេះ នឹងផ្តល់ជំនួយហិរញ្ញវត្ថុ ទៅអោយក្រុមប្រឹក្សាឃុំដែលទើបជាប់ឆ្នោត ដែលត្រូវជ្រើសរើស និងផ្តល់មូលនិធិបន្ត សំរាប់ធ្វើអោយប្រសើរឡើង ដល់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច និងការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបទៅនឹងតំរូវការដែលបានលើកឡើងរបស់ប្រជាពលរដ្ឋមូលដ្ឋានក្នុងឃុំ ។ បើពិនិត្យលើចំណងជើងរបស់គំរោង យើងឃើញថា គំរោងនេះមានទិសដៅ**ពីរ**សំខាន់ៗគឺ

- **ទី១** : ដើម្បីគាំទ្រដល់ការធ្វើអោយ ហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និងការផ្តល់សេវាសាធារណៈប្រសើរឡើងតាមរយៈការវិនិយោគ និង
- **ទី២** : ដើម្បីបង្កើនការចូលរួមមូលដ្ឋាន (ទាំងថ្នាក់ភូមិ និងថ្នាក់ឃុំ) ក្នុងការធ្វើសេចក្តីសំរេច ។

២. ពេលបច្ចុប្បន្ននេះ ទិសដៅ និងនីតិវិធីរបស់កម្មវិធីសីលា មិនទាន់បានពិចារណាអោយបានច្បាស់លាស់ អំពីផលប៉ះពាល់របស់កម្មវិធីទៅលើជនជាតិភាគតិចនានាដែលរស់នៅ ក្នុងខេត្តដែលអនុវត្តកម្មវិធីសិលា នៅឡើយទេ ។ ទោះជាយ៉ាងណាក៏ដោយគំរោង **RILGP** ត្រូវឆ្លើយតបទៅនឹងតំរូវការនានាដែលមាន នៅក្នុងសេចក្តីណែនាំប្រតិបត្តិលេខ ៤.២០ របស់ធានាគារពិភពលោក (ស្តីពីប្រជាជននៅតំបន់ខ្ពង់រាប) ។ សេចក្តីណែនាំនេះ បានចែងថា វិធានការពិសេស១សំរាប់កសាងផែនការ ត្រូវតែបង្កើតឡើង ដើម្បីការពារផលប្រយោជន៍របស់ជនជាតិភាគតិចដែលមានចរិកលក្ខណៈខុសៗគ្នា ដែលលក្ខណៈនេះ អាចនឹងធ្វើអោយពួកគេងាយរងគ្រោះ ចំពោះការខូចប្រយោជន៍ក្នុងដំណើរការអភិវឌ្ឍន៍ ។ ទិសដៅចំបងនៃសេចក្តីណែនាំនេះ គឺ :

ក). ធ្វើអោយប្រាកដថា ក្រុមជនជាតិដើមភាគតិចទាំងនេះ ទទួលបានឱកាសប្រកបដោយអត្ថន័យ ក្នុងការចូលរួមកសាងផែនការដែលអាចមានផលប៉ះពាល់ដល់ពួកគេ ។

ខ). ធ្វើអោយប្រាកដថា ឱកាសដែលបានផ្តល់អោយពួកគេ ត្រូវអោយស្របទៅតាមលក្ខណៈវប្បធម៌សមស្របផ្សេងៗគ្នារបស់ពួកគេ ។

គ). ធ្វើអោយប្រាកដថា ផលប៉ះពាល់មិនល្អផ្សេងៗរបស់គំរោងទៅលើពួកគេ ត្រូវបានជៀសវាង ឬបើមិនអញ្ចឹងត្រូវបានសំរួលអោយមានតិចតួចបំផុត ។

៣. ធានាគារបានកំណត់ថា សេចក្តីណែនាំប្រតិបត្តិលេខ ៤.២០ ត្រូវអនុវត្តចំពោះ "**ប្រជាជនតំបន់ខ្ពង់រាប**" ដែលនៅរក្សាទំនៀមទំលាប់វប្បធម៌ និងការអនុវត្តក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ខុសពីការអនុវត្តរបស់ជនជាតិខ្មែរភាគច្រើន ។ ឯកសារនេះពណ៌នាពីសកម្មភាពដែលត្រូវអនុវត្ត ឬដែលត្រូវបានអនុវត្តដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីធានាអោយការរៀបចំគំរោង ឆ្លើយតបទៅនឹងតំរូវការនានារបស់សេចក្តីណែនាំប្រតិបត្តិ លេខ៤.២០ ។ ដោយសារគំរោង **RILGP** ជាគំរោងមួយផ្តល់អំណាចដល់សហគមន៍មូលដ្ឋានដើម្បីកំណត់សកម្មភាពអភិវឌ្ឍន៍ជាអាទិភាពរបស់ខ្លួន ដូច្នេះ **RILGP** មានលក្ខណៈពិសេសសំខាន់ៗចំនួន២ ក្នុងការរៀបចំផែនការ ដើម្បីការពារផលប្រយោជន៍របស់ជនជាតិភាគតិចទាំងនេះ :

៤. **ទីមួយ** ក្នុងគំរោង **RILGP** ដំណើរការនៃការដាក់អាទិភាពលើតំរូវការថ្នាក់ភូមិ និងការជ្រើសរើសសកម្មភាពជាអាទិភាពថ្នាក់ឃុំ គឺត្រូវធ្វើឡើងនៅក្នុងកំឡុងពេលអនុវត្តគំរោងតែប៉ុណ្ណោះ ។ ដូច្នេះ យើងមិនអាចធ្វើការវាយតំលៃជាមុនលើលក្ខណៈសមស្រប និងផលប៉ះពាល់របស់សកម្មភាពដែលត្រូវទទួលមូលនិធិគាំទ្រពីគំរោងបានឡើយ។

៥. **ទីពីរ** ផែនការត្រូវផ្តោតជាពិសេសទៅលើគោលដៅមួយ គឺ ធានាអោយមានឱកាសសមស្រប សំរាប់ការចូលរួមពីមូលដ្ឋានទាំងនៅថ្នាក់ភូមិ និងថ្នាក់ឃុំ ។ តាមនិយមន័យ បើសិនជាមានការចូលរួមសមស្របសកម្មភាពនានារបស់គំរោង ដែលឆ្លើយតបទៅនឹងតំរូវការនានា ដែលកំណត់ដោយអ្នកភូមិខ្លួនឯង នឹងត្រូវបានចាត់ទុកថា "សមស្របទៅតាមវប្បធម៌របស់ពួកគេ" ។ ស្រដៀងគ្នានេះដែរ បើសិនជាមានការចូលរួមសមស្រប គឺវាមិនមានមូលដ្ឋានណាមួយដែលយើងគិតថា មានភូមិណាមួយបានទទួល "ផលប៉ះពាល់មិនល្អ" ដែលជាផលវិបាកផ្ទាល់នៃសកម្មភាពអភិវឌ្ឍន៍ដែលភូមិខ្លួនឯងបានលើកឡើងនោះទេ។

៦. ដូច្នេះ ធាតុសំខាន់ៗនៅក្នុងផែនការនេះ គឺ :

   ក). ដើម្បីប្រាកដថា តាមរយៈការគ្រោងគំរោង និងការរៀបចំការតាមដាន ប្រជាពលរដ្ឋតំបន់ខ្ពង់រាបទទួលបានឱកាសចូលរួមក្នុងការចាត់អាទិភាពលើតំរូវការទាំងឡាយរបស់ពួកគេ ។

   ខ). ដើម្បីប្រាកដថា សេចក្តីត្រូវការដែលបានលើឡើងរបស់ពួកគេ ត្រូវបានបង្ហាញនៅថ្នាក់ឃុំ ។

   គ). ដើម្បីប្រាកដថា ការជ្រើសរើសសកម្មភាពអភិវឌ្ឍន៍នៅថ្នាក់ឃុំ សំរាប់ផ្តល់មូលនិធិ គឺឆ្លើយតបទៅនឹងអាទិភាពរបស់ប្រជាពលរដ្ឋនៅតំបន់ខ្ពង់រាបយ៉ាងសមស្រប ។

ប្រជាពលរដ្ឋតំបន់ខ្ពង់រាប និងសេចក្តីណែនាំសំរាប់ប្រតិបត្តិការលេខ ៤.២០

៧. រាជរដ្ឋាភិបាលកម្ពុជា មិនបានរក្សាទុកស្ថិតិជាផ្លូវការ ស្តីពីបញ្ហាជនជាតិដើមភាគតិចឡើយ ហើយស្ថិតិនៃការប៉ាន់ស្មានពីប្រជាសាស្ត្រ និងការបែងចែកភូមិសាស្ត្ររបស់ជនជាតិដើមភាគតិចដែលមានបច្ចុប្បន្ននេះ គឺតិចតួចណាស់ ហើយក៏មិនត្រឹមត្រូវទាំងស្រុងដែរ ។ ក្នុងឆ្នាំ១៩៩២ មុនពេលការបញ្ចប់ការងាររបស់ខ្លួន នាយកដ្ឋានជនជាតិដើមភាគតិច បានចុះបញ្ជីជនជាតិដើមភាគតិចចំនួន៣៥ក្រុម ហើយបានប៉ាន់ប្រមាណថា

សមាមាត្ររបស់ជនជាតិដើមភាគតិចទាំងនេះ គឺប្រហែលទៅនឹង៤% នៃចំនួនប្រជាពលរដ្ឋសរុប ។ ក្នុងឆ្នាំ ១៩៩៥ ក្រសួងមហាផ្ទៃ ក៏បានធ្វើការប៉ាន់ស្មានដែលមានសមាមាត្រស្រដៀងគ្នានេះផងដែរ ។

៨. ក្រុមជនជាតិដែលមានចំនួនច្រើនជាងគេ ក្នុងនោះមានដើមកំណើតជាជនជាតិវៀតណាម ចិន ឥស្លាម និងជនជាតិភាគតិចឡាវ នៅក្នុងបរិបទប្រទេសកម្ពុជា ជាទូទៅ មិនត្រូវបានចាត់ទុកថាជា "**ជនជាតិដើមភាគតិចទេ**" ហើយជាទូទៅ ក៏មិនបានចាត់ចូលទៅក្នុងចរឹកលក្ខណៈដែលងាយរងគ្រោះ ដូចដែលបានលើកឡើង ក្នុងសេចក្តីណែនាំប្រតិបត្តិការលេខ៤.២០នោះដែរ ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រជាជនខ្មែរភាគច្រើនបានចាត់ទុកជនជាតិមួយក្រុមនេះជាទូទៅថាជា "**ខ្មែរលើ**" ឬតាមន័យភាសាអង់គ្លេស "**ខ្មែរផ្នែកខាងលើ ឬ ប្រជាពលរដ្ឋតំបន់ខ្ពង់រាប**" ថាជាជនជាតិដើមភាគតិច និងដែលមានវប្បធម៌ និងការរស់នៅប្រចាំថ្ងៃរបស់ពួកគេ ខុសគ្នាពីជនជាតិភាគតិច ។ ចរឹកលក្ខណៈដែលងាយរងគ្រោះរបស់ក្រុមជនជាតិដើមភាគតិចនេះ គឺមានចែងនៅក្នុងសេចក្តីណែនាំប្រតិបត្តិលេខ៤.២០ :

ក). ជាប់ទាក់ទងនឹងទឹកដី និងធនធានពីដូនតា

ខ). ពឹងផ្អែកលើផលិតកម្មសំរាប់ផ្គត់ផ្គង់តែជីវភាពប្រចាំថ្ងៃ

គ). ខ្លួនឯង ឬអ្នកដទៃ ផ្តល់អត្តសញ្ញាណថា ជាក្រុមខុសប្លែកពីគេ

ឃ). ប្រើភាសាខុសពីភាសាដែលគេប្រើប្រាស់ភាគច្រើន ឬភាសាផ្លូវការ នៅក្នុងប្រទេស

ង). ពឹងផ្អែកលើវប្បធម៌ និងសង្គមសេដ្ឋកិច្ចតាមទំនៀមទំលាប់ប្រពៃណី

៩. ទោះបីជាចំនួនរបស់ពួកគេ ហាក់ដូចជាតិចតួចបន្តិចមែនធៀបទៅនឹងចំនួនប្រជាពលរដ្ឋសរុបទូទាំងប្រទេស ប៉ុន្តែវាជាចំនួនមួយដ៏ច្រើន ក្នុងចំណោមប្រជាពលរដ្ឋសរុបនៅភូមិភាគឦសានក្នុងខេត្តរតនគីរី និងខេត្តមណ្ឌលគីរី។ ក្រុមជនជាតិដើមភាគតិចនេះ មានសមាមាត្រតិចតួចណាស់ នៅក្នុងខេត្តផ្សេងៗទៀត ។ ក្នុងចំណោមជនជាតិដើមភាគតិចទាំងនេះមាន ទំពួន កួយ ចារាយ ភ្នង គ្រឹង ការ៉ៃត ព្រូ ស្ទៀង លួន និងក្រុមផ្សេងៗទៀត សរុបប្រមាណ ១២០.០០០នាក់ ឬស្មើនឹងជាង ១% នៃប្រជាពលរដ្ឋសរុបទូទាំងប្រទេស។

១០. ក្នុងឆ្នាំ២០០២ ការសិក្សាពិនិត្យជ្រើសរើសជនជាតិដើមភាគតិចដែលរស់នៅតំបន់ខ្ពង់រាប ត្រូវបានធ្វើឡើងជាផ្នែកមួយនៃការរៀបចំគំរោង **RILGP** ដើម្បីវាយតំលៃថា តើមនុស្សដែលរស់នៅក្នុងតំបន់គោលដៅរបស់គំរោងមានចរឹកលក្ខណៈខុសគ្នាបែបណាខ្លះ ធៀបទៅនឹងចរឹកលក្ខណៈដែលបានពណ៌នានៅក្នុងសេចក្តីណែនាំប្រតិបត្តិលេខ៤.២០ និងដើម្បីពិគ្រោះយោបល់ជាមួយសហគមន៍ជនជាតិដើមភាគតិចដែលអាចមានការពាក់ព័ន្ធ ស្តីពីជំរើសរបស់ពួកគេ លើការរៀបចំ និងអនុវត្តន៍គំរោង ។ ការសិក្សានោះបានសន្និដ្ឋានថា ប្រជាពលរដ្ឋតំបន់ខ្ពង់រាប ក្នុងខេត្តរបស់គំរោង ដូចជាខេត្តរតនគីរី ក្រចេះ ព្រះវិហារ និងខេត្ត កំពង់ស្ពឺ គឺមានចរឹកលក្ខណៈផ្សេងៗគ្នា ដូចដែលមានចែងនៅក្នុងសេចក្តីណែនាំប្រតិបត្តិលេខ៤.២០ ។ ការពិគ្រោះយោបល់នេះ ក៏បានគូសបញ្ជាក់ថា ការគាំទ្រដ៏ទូលំទូលាយ និងដែលមានប្រជាប្រិយភាព សំរាប់ការចូលរួម

ក្នុងគំរោង និងកិច្ចព្រមព្រៀងដ៏ទូលំទូលាយ ដែលបានលើកឡើងនូវការរៀបចំ សំរាប់ការអនុវត្ត គឺទទួលបានការពេញចិត្តពីសហគមន៍មូលដ្ឋាន។

១១. សកម្មភាពខ្នាតតូចដែលបានជ្រើសរើសដោយអ្នកភូមិ និងដែលបានផ្តល់មូលនិធិដោយគំរោង **RILGP** នឹងមិនបណ្តាលអោយមានផលប៉ះពាល់ដល់ម្ចាស់ដី ឬក៏មិនបណ្តាលអោយមានឥទ្ធិពលមិនល្អដោយផ្ទាល់ឡើយ ។ ទោះបីយ៉ាងណាក៏ដោយ ការសិក្សាបានអះអាងថា របៀបរបប និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតំបន់ខ្ពង់រាប គឺទទួលរងនូវសម្ពាធ ក្នុងតំបន់មួយចំនួន ដោយសារតែមានការផ្លាស់ទីលំនៅរបស់អ្នកផ្សេងៗ ចូលទៅក្នុងតំបន់រស់នៅរបស់ពួកគេ កម្មវិធីសម្បទានព្រៃឈើ ព្រមទាំងមិនមានការលើកទឹកចិត្តក្នុងការផ្លាស់ប្តូររបៀបរបបធ្វើកសិកម្ម ។ សកម្មភាពនានាធ្វើអោយប្រសើរឡើងដល់សេវាកម្ម និងហេដ្ឋារចនាសម្ព័ន្ធដែលផ្តល់ហិរញ្ញវត្ថុដោយគំរោង **RILGP** គួរតែអាចកាត់បន្ថយចរន្តហូរចូលនៃអ្នកផ្លាស់ទីលំនៅក្នុងពេលអនាគត និងដាក់សម្ពាធលើលទ្ធភាពទទួលយកធនធាននានាក្នុងតំបន់របស់គំរោង ។ ដោយហេតុផលបែបនេះ ប្រជាពលរដ្ឋតំបន់ខ្ពង់រាប ត្រូវបានចាត់ទុកថា ងាយនឹងជួបការលំបាកក្នុងដំណើរការអភិវឌ្ឍន៍ ហើយផែនការនេះក៏ត្រូវពិនិត្យឡើងវិញផងដែរ លើសកម្មភាពទាំងឡាយដែលបានអនុវត្ត ឬនឹងត្រូវអនុវត្តដើម្បីការពារប្រយោជន៍របស់ពួកគេ ។ ជាទូទៅ ការរៀបចំសំរាប់ការចូលរួមក្នុងកម្មវិធីសិលា ត្រូវតែអោយមានលក្ខណៈជាបែបបទឯកភាពមួយ ។ ការរៀបចំសំរាប់ការចូលរួមដែលមានលក្ខណៈឯកភាពបែបនេះ នឹងផ្តល់ប្រយោជន៍ដល់ជនជាតិខ្មែរភាគច្រើន និងក្រុមជនជាតិដើមភាគតិចដទៃទៀតផងដែរ ។ វិធានការ ឬការចាត់ចែង ជាពិសេសណាមួយ សំដៅជាពិសេសដល់ប្រជាពលរដ្ឋតំបន់ខ្ពង់រាប ត្រូវតែបោះពុម្ពជាអក្សរ ទ្រេតទាំងអស់ ។

បរិបទច្បាប់របស់កម្ពុជា

១២. នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ប្រជាពលរដ្ឋតំបន់ខ្ពង់រាបទាំងអស់ ត្រូវមានសិទ្ធិទទួលបានសញ្ជាតិជាពលរដ្ឋកម្ពុជា ។ តែទោះជាបែបនេះក៏ដោយ ពេលបច្ចុប្បន្ននេះ មិនទាន់មានឥតិកម្ម ឬបទបញ្ជាតិណាមួយអោយបានទូលំទូលាយនៅឡើយទេ ដែលទាក់ទងជាពិសេស ដល់ការការពារសិទ្ធិ និងផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងនេះ។

១៣. នៅក្នុងឆ្នាំ១៩៩៧ គណៈកម្មាធិការអន្តរក្រសួងសំរាប់ការអភិវឌ្ឍន៍ពលរដ្ឋតំបន់ខ្ពង់រាប បានចេញសេចក្តីព្រាងមួយដែលមានចំណងជើងថា "**គោលនយោបាយទូទៅសំរាប់អភិវឌ្ឍន៍ពលរដ្ឋតំបន់ខ្ពង់រាប**" ។ សេចក្តីព្រាងដែលត្រូវបានបញ្ចប់ដោយត្រូវឆ្លងកាត់ដ៏វែងឆ្ងាយ ចាប់តាំងពីការពិគ្រោះយោបល់ជាមួយក្រុមមូលដ្ឋាន អង្គការមិនមែនរដ្ឋាភិបាល ភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិ និងរដ្ឋាភិបាល គឺមកដល់ពេលនេះមិនទាន់ទទួលបានការអនុម័តជាផ្លូវការពីរដ្ឋាភិបាលនៅឡើយទេ ។ សេចក្តីប្រកាសពីគោលនយោបាយនេះបានផ្តល់នូវការការពារមួយចំនួនដល់ពលរដ្ឋទាំងនេះ ដែលភាគច្រើនទាក់ទងទៅនឹងសិទ្ធិកាន់កាប់ដីធ្លី និង

លទ្ធភាពទទួលយកធនធាន ។ សារៈសំខាន់ពិសេសនៅក្នុងបរិបទរបស់គំរោង **RILGP** គឺល័ក្ខខ័ណ្ឌ ចែងទាំងឡាយ ដែលមាននៅក្នុងគោលនយោបាយទូទៅនេះឯង ដូចជា :

- រដ្ឋាភិបាល "ត្រូវជំរុញអោយមានការយោគយល់ និងការគោរពដល់វប្បធម៌ផ្សេងៗគ្នារបស់ពូកគេ ព្រមទាំងត្រូវធានាថា ប្រជាពលរដ្ឋតំបន់ខ្ពង់រាបទាំងនេះ អាចអនុវត្តប្រពៃណីវប្បធម៌ផ្ទាល់ខ្លួនរបស់គេបាន" (ក្នុងកថាខ័ណ្ឌទី១)
- ប្រជាពលរដ្ឋតំបន់ខ្ពង់រាប មានសិទ្ធិពេញលេញក្នុងការទទួលបានពត៌មាន និងក្នុងការធ្វើសេចក្តីសំរេចចិត្តលើអាទិភាពនានា និងពិនិត្យមើលលើសេដ្ឋកិច្ច សង្គម និងវប្បធម៌របស់ពូកគេ (កថាខ័ណ្ឌទី៦)

លក្ខខ័ណ្ឌចែងខាងក្រោមមួយនេះ មាននៅក្នុងផ្នែកគោលនយោបាយណែនាំ នៃសេចក្តីព្រាងនេះ :

- សហគមន៍ប្រជាពលរដ្ឋតំបន់ខ្ពង់រាប នឹងមានឱកាសចូលរួម និងទទួលខុសត្រូវលើរាល់សេចក្តីសំរេចចិត្តដែលទាក់ទងទៅនឹងគំរោងហេដ្ឋារចនាសម្ព័ន្ធដែលមានផលប៉ះពាល់ដល់ពូកគេ ។ សហគមន៍ និងបុគ្គលដែលទទួលផលប៉ះពាល់ពីគំរោង ត្រូវតែបានយល់ស្រប ក្រោយពីទទួលបានពត៌មានយ៉ាងពេញលេញដោយប្រើភាសាដែលគេអាចយល់បានស្តីពីគំរោង និងរាល់ផលវិបាកទាំងឡាយដែលពូកគេនឹងជួបប្រទះ និងបរិយាកាសធម្មជាតិរបស់ពូកគេ មុនពេលគំរោងអភិវឌ្ឍន៍ទាំងនេះ ត្រូវបានចាប់ផ្តើមដំណើរការបាន (កថាខ័ណ្ឌ ៧.២) ។

១៤. ក្នុងពេលគំរោង **RILGP** សេចក្តីព្រាង "គោលនយោបាយទូទៅសំរាប់អភិវឌ្ឍន៍ប្រជាពលរដ្ឋតំបន់ខ្ពង់រាប" គឺកំពុងស្ថិតនៅក្នុងការពិចារណារបស់រដ្ឋាភិបាលនៅឡើយ ។ សំរាប់គោលបំណងរបស់គំរោង **RILGP** ព្រះរាជាណាចក្រកម្ពុជាបានយល់ស្របក្នុងការប្រើវិធានការនានា ដែលស៊ីសង្វាក់ទៅនឹងល័ក្ខខ័ណ្ឌរបស់គោលនយោបាយខាងលើ ដើម្បីដឹកនាំការលើកគំរោង និងរៀបចំការអនុវត្តន៍គំរោង ។ វិធីសាស្ត្រជាក់លាក់មួយចំនួន ដើម្បីធានាអោយមានឱកាសសមស្របចូលរួមក្នុងដំណើរការធ្វើសេចក្តីសំរេចចិត្ត ទាំងនៅថ្នាក់ភូមិ និងថ្នាក់ឃុំ គឺត្រូវបានពន្យល់ក្នុងផ្នែកខាងក្រោមនេះ ។

ការរៀបចំការចូលរួមនៅថ្នាក់ភូមិ

១៥. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាឯកសារជាមូលដ្ឋាននានា ស្តីពីយុទ្ធនាការវិមជ្ឈការរបស់រដ្ឋាភិបាល បានទទួលស្គាល់ឃុំថា ជារដ្ឋាភិបាល និងរដ្ឋបាលថ្នាក់មូលដ្ឋាន ដែលទូទៅ ភូមិ គឺជាចំណុចសរីរាង្គនៃនិវាសដ្ឋាន ដោយគ្មានជំហរតាមច្បាប់ជាផ្លូវការ ។ ទោះជាយ៉ាងនេះក៏ដោយ ការអនុវត្តច្បាប់ និងបទបញ្ជាតិនានា បានចែងថា គោលបំណងជាចំបងរបសវិមជ្ឈការទៅថ្នាក់ឃុំ គឺដើម្បីជំរុញអោយមានការឆ្លើយតបចំពោះតំរូវការ និងផលប្រយោជរបស់អ្នកស្រុកមូលដ្ឋាន ។

១៦. ឯកសារជាមូលដ្ឋាននានាសំរាប់យុទ្ធនាការវិមជ្ឈការរដ្ឋាភិបាលរួមមាន :

- "ច្បាប់គ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់" (ខែមិនា ២០០១)
- "ប្រកាសរបស់អន្តរក្រសួងស្តីពីការកសាងផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់" (ខែមករា ២០០២)
- "អនុក្រឹត្យស្តីពីការធ្វើវិមជ្ឈការអំណាច តួនាទី និងការកិច្ចទៅអោយក្រុមប្រឹក្សាឃុំ សង្កាត់" (ខែមិនា ២០០២)
- "សេចក្តីណែនាំស្តីពីការកសាងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់" (ខែមេសា ២០០២)

១៧. ដោយសារឯកសារទាំងនេះ ជាប់ពាក់ព័ន្ធជាសំខាន់ទៅលើតួនាទី និងការទទួលខុសត្រូវ ដែលបានផ្តល់ទៅអោយមន្ត្រីថ្នាក់ឃុំ គឺឯកសារទាំងនេះចែងថា ប្រជាពលរដ្ឋក្នុងភូមិ មានសិទ្ធិចូលរួម ក្នុងការចាត់អាទិភាពតំរូវការរបស់ខ្លួន ព្រមទាំងផ្តែកផ្សេងៗទៀតសំរាប់ការកសាងផែនការ និងការអនុវត្តគំរោង ។ ដើម្បីធានាថា ប្រជាពលរដ្ឋតំបន់ខ្ពង់រាប អាចចូលរួមយ៉ាងពេញលេញនៅថ្នាក់ភូមិ ក្នុងការកំណត់ និងចាត់អាទិភាពតំរូវការនានារបស់ខ្លួន គឺត្រូវអនុវត្តការរៀបចំមួយចំនួនដូចខាងក្រោមនេះ :

ការផ្តល់ពត៌មាន និងការសំរបសំរួល

១៨. ដើម្បីផ្តួចផ្តើមវដ្តនៃការកសាងផែនការនៅថ្នាក់ឃុំ មន្ត្រីថ្នាក់ឃុំត្រូវធ្វើការវាយតំលៃស្ថានភាពរស់នៅ និងល័ក្ខខ័ណ្ឌហេដ្ឋារចនាសម្ព័ន្ធនៅក្នុងឃុំរបស់ខ្លួន ហើយផ្តល់លទ្ធផលវាយតំលៃទាំងនោះទៅអោយភូមិនីមួយៗក្នុងឃុំរបស់ខ្លួន ។ អ្នកភូមិទាំងអស់ ក៏នឹងត្រូវបានផ្តល់ពត៌មានពីការរៀបចំកម្មវិធី ដោយសារពួកគេត្រូវចូលរួម ក្នុងការកំណត់អាទិភាព កសាងផែនការលំអិត និងការអនុវត្តសកម្មភាពរបស់គំរោង **RILGP** ។

១៩. គំរោង **RILGP** តំរូវអោយក្រុមអ្នកសំរបសំរួលស្រុកផ្សព្វផ្សាយពត៌មានទៅដល់ភូមិ និងត្រូវពន្យល់អំពីនីតិវិធីរបស់កម្មវិធីសិលា ព្រមទាំងត្រូវធានាថា អ្នកភូមិទាំងអស់យល់ដឹងច្បាស់ថា ពួកគេមានឱកាសចូលរួមនៅក្នុងការកសាងផែនការភូមិ សំរាប់ភូមិរបស់គេ ។

នៅក្នុងភូមិដែលមានប្រជាពលរដ្ឋតំបន់ខ្ពង់រាបរស់នៅ ពត៌មាន នឹងត្រូវបានផ្សព្វផ្សាយ ហើយការសំរបសំរួល នឹងត្រូវបានធ្វើឡើង ដោយប្រើភាសាមួយ ដែលអ្នកភូមិទាំងអស់អាចយល់បាន ។ ជាងនេះទៅទៀត អ្នកសំរបសំរួលដែលធ្វើការជាមួយប្រជាពលរដ្ឋទាំងនោះ ត្រូវធានាថាពួកគេទទួលបានឱកាសពិចារណាលើការផ្លាស់ប្តូរសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ។

ការពិភាក្សា និងការវិភាគនៅថ្នាក់ភូមិ

២០. រៀងរាល់ឆ្នាំ ភូមិនីមួយ១ដែលចូលរួមជាមួយកម្មវិធី នឹងរៀបចំការប្រជុំ ឬសិក្ខាសាលាចំហរមួយ ដើម្បីពិនិត្យឡើងវិញ អំពីព្រឹត្តិការណ៍ជាក់លាក់មួយចំនួននៅក្នុងភូមិ ហើយដើម្បីបង្កើតជាបញ្ជីអាទិភាព សំរាប់កែលំអភូមិ រួមទាំងការធ្វើអោយប្រសើរឡើងដល់ហេដ្ឋារចនាសម្ព័ន្ធខ្នាតតូចផងដែរ ។ អ្នកភូមិទាំងអស់អាចចូលរួម (ក្នុងនាមជាបុគ្គលម្នាក់ៗ ឬអាចជាសមាជិកនៃសមាគមណាមួយក៏បាន)។ ទំរង់នៃការប្រជុំ ឬសិក្ខាសាលាជាចំហរនេះ អាចមានលក្ខណៈខុសៗគ្នាពីមួយទៅមួយ ។ ក្នុងភូមិមួយចំនួន ការប្រជុំបែបនេះអាចដឹកនាំ ឬសំរបសំរួលដោយអ្នកតំណាងភូមិ ដែលជាមាជិកគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ (គ.ផ.ថ) ។ ហើយនៅកន្លែងផ្សេងទៀត ការប្រមូលផ្តុំបើកចំហរក្រៅផ្លូវការ អាចសមស្របជាង ដើម្បីអោយស្របទៅនឹងការអនុវត្តជាក់ស្តែងនៅថ្នាក់មូលដ្ឋាន ។ នីតិវិធីធ្វើសុពលភាពរបស់កម្មវិធីសិលា បានតំរូវថា យ៉ាងហោចណាស់ត្រូវមាន ៧0%នៃអ្នកភូមិទាំងអស់ ចូលរួមក្នុងការកំណត់ និងចាត់អាទិភាពតំរូវការ ។

២១. បញ្ជីអាទិភាពដែលបានបង្កើតឡើងនៅក្នុងភូមិនីមួយ១ នឹងត្រូវបានធ្វើសុពលភាពជាផ្លូវការដោយ គ.ផ.ថ (សូមមើលក្នុងផ្នែកខាងក្រោម) ។ បញ្ជីអាទិភាពនេះ ត្រូវផ្តល់ដោយភូមិនីមួយ១ ហើយបញ្ជីនេះ គឺជាមូលដ្ឋានដ៏សំខាន់មួយ សំរាប់បង្កើតផែនការអភិវឌ្ឍន៍រួមរបស់ឃុំ និងសំរាប់ការជ្រើសរើស ដើម្បីធ្វើអោយប្រសើរឡើងដល់ហេដ្ឋារចនាសម្ព័ន្ធ ឬការផ្តល់សេវាសាធារណៈខ្នាតតូច ក្រោមគំរោង RILGP ។

អ្នកតំណាងភូមិ

២២. ទោះបីជាសមាជិកក្រុមប្រឹក្សាឃុំនីមួយ១ ត្រូវបានបោះឆ្នោតជ្រើសរើសដោយប្រជាពលរដ្ឋក្នុងឃុំក៏ដោយ ក៏មិនបានតំរូវអោយភូមិទាំងអស់ ត្រូវតែមានអ្នកតំណាងដោយផ្ទាល់របស់ខ្លួន នៅក្នុងជួរសមាជិកក្រុមប្រឹក្សាឃុំនោះទេ ។ សមាជិកនៃក្រុមប្រជាពលរដ្ឋតំបន់ខ្ពង់រាប គឺមិនមែនគ្មានលក្ខណៈសម្បត្តិសមស្រប ដើម្បីឈរឈ្មោះជាសមាជិកក្រុមប្រឹក្សានោះទេ ប៉ុន្តែច្បាប់បានកំណត់ថា សមាជិកក្រុមប្រឹក្សា ត្រូវចេះអាន និងសរសេរភាសាខ្មែរ ។ ដើម្បីធានាអោយមានតំណាងស្មើគ្នាពីភូមិនីមួយ១ ក្នុងក្នុងឃុំ គ.ផ.ថ ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ការប្រឹក្សាដល់ក្រុមប្រឹក្សាឃុំ ។

២៣. ភូមិនីមួយ១ មានតំណាង២នាក់នៅក្នុងគណៈកម្មាធិការនេះ ។ ទោះបីជាតំណាងទាំងនេះត្រូវបានតែងតាំងជាផ្លូវការដោយក្រុមប្រឹក្សាឃុំក៏ដោយ ប៉ុន្តែពួកគេត្រូវបានជ្រើសរើសក្នុងចំណោមមនុស្សទាំងឡាយដែលអ្នកភូមិបានតែងតាំង មុនពេលរៀបចំបញ្ជីអាទិភាពភូមិ ។ ដើម្បីជំរុញសមភាពយេនឌ័រ ក្នុងអភិបាលកិច្ចមូលដ្ឋាន ក្រុមប្រឹក្សាឃុំ នឹងតែងតាំងយ៉ាងហោចណាស់ ស្ត្រីមួយរូបសំរាប់តំណាងអោយភូមិនីមួយ១ ។ បន្ថែមលើការតែងតាំងតំណាងពីររូបមកពីភូមិនីមួយ១ មេឃុំ អាចជ្រើសរើសអ្នកតំណាងភូមិចំនួន៤នាក់ផ្សេងទៀត អោយបំរើការជាសមាជិក ក្នុងគណៈកម្មាធិការផ្តល់យោបល់ ។

ជាទូទៅ ពតិមានដែលមានស្រាប់ បានបង្ហាញថា ភូមិដាច់ស្រយាលបំផុតក្នុងភូមិភាគឧត្តរ និងឦសាន នៃប្រទេសកម្ពុជា គឺអាចមានពូជអំបូរតែមួយជាកុលសម្ព័ន្ធភាគច្រើន ឬតិច ឬមានចំនួនសមាជិកក្រុមប្រជាពលរដ្ឋតំបន់ខ្ពង់រាបច្រើនលើសលុប ។ ចំពោះភូមិដែលមានអំបូរផ្សេងៗគ្នា ដែលមានសមាមាត្រភាគច្រើន (ឧទាហរណ៍ មានច្រើនជាងមួយភាគបី) នៃប្រជាពលរដ្ឋតំបន់ខ្ពង់រាប ក្រុមប្រឹក្សាឃុំត្រូវធានាអោយបានថា ប្រជាពលរដ្ឋទាំងនោះ មានតំណាងតំណាងរបស់ខ្លួន នៅក្នុងជួរគណៈកម្មាធិការផ្តល់យោបល់នេះ ទោះបីជាពួកគេត្រូវបាមតែងតាំងជាតំណាងភូមិ ឬជាសមាជិកដែលបានជ្រើសរើសដោយមេឃុំក៏ដោយ ។

ការរៀបចំសំរាប់ការធ្វើសេចក្តីសំរេចថ្នាក់ឃុំ

២៤. ដូចដែលបានលើកឡើងនៅខាងលើ ប្រជាពលរដ្ឋក្នុងភូមិ ត្រូវបង្កើតអាទិភាពផ្ទាល់របស់ពួកគេដើម្បីកែលំអហេដ្ឋារចនាសម្ព័ន្ធក្រោមគំរោង RILGP និងដែលជាអ្នកតំណាងដោយផ្ទាល់ក្នុងការកសាងផែនការអភិវឌ្ឍន៍ថ្នាក់ឃុំ តាមរយៈ គ.ផ.ឃ ។ ដោយមានការចូលរួមតំណាងភូមិ នៅក្នុង គ.ផ.ឃ អ្នកភូមិទាំងឡាយ មានឱកាសប្រើប្រាស់ឥទ្ធិពលរបស់ខ្លួន នៅក្នុងដំណាក់កាលផ្សេងៗ នៃការធ្វើសេចក្តីសំរេចថ្នាក់ឃុំ ។

២៥. មុនពេលការរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំ សមាជិក គ.ផ.ឃ នឹងពិនិត្យបញ្ជីអាទិភាពរបស់ភូមិឡើងវិញ ហើយនឹងបង្កើតទិសដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ឃុំរយៈពេលវែង ។
នៅក្នុងឃុំដែលមានភូមិរបស់ប្រជាពលរដ្ឋនៅតំបន់ខ្ពង់រាបរស់នៅ នីតិវិធីរបស់កម្មវិធីសិលា តំរូវអោយអ្នកតំណាងក្រុមជនជាតិដើមភាគតិចចូលរួមក្នុងដំណើរការបង្កើតទិសដៅ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ឃុំ ហើយកំណត់ហេតុនៃដំណើរការនោះ ក៏ត្រូវកត់ត្រាទុកជាឯកសារផងដែរ ។

២៦. ក្នុងកំឡុងពេលដំណើរការបង្កើតផែនការអភិវឌ្ឍន៍ឃុំ ការប្រជុំនៅថ្នាក់ភូមិមួយ ឬច្រើនត្រូវបានធ្វើឡើងដើម្បីសំរេចអោយបានប្រការមួយចំនួនដូចខាងក្រោម :

ក). គ.ផ.ឃ នឹងរៀបចំសេចក្តីព្រាងផែនការអភិវឌ្ឍន៍ឃុំមួយ ដើម្បីដាក់អោយក្រុមប្រឹក្សាឃុំពិចារណា ។ មុនពេលក្រុមប្រឹក្សាឃុំធ្វើការពិចារណា សេចក្តីព្រាងផែនការនេះ នឹងត្រូវបានផ្សព្វផ្សាយដល់ប្រជាជនទាំងអស់ក្នុងឃុំ ដើម្បីផ្តល់យោបល់ ។

ខ). សេចក្តីព្រាងផែនការអភិវឌ្ឍឃុំនេះ នឹងរួមបញ្ចូលការបញ្ជាក់យ៉ាងច្បាស់ពីគំរោង ដោយមានផែនទី និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។ ក្នុងភូមិដែលមានសកម្មភាពអភិវឌ្ឍន៍ទាំងនេះ ការប្រជុំជាចំហរមួយនៅថ្នាក់ភូមិ នឹងត្រូវបានធ្វើឡើង ដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវរបស់ផែនទី និងឯកសារដែលពាក់ព័ន្ធ។

គ). បើសិនផែនការអភិវឌ្ឍន៍ឃុំ ទាមទារអោយអ្នកភូមិចូលរួមទុនបដិភាគជាសាច់ប្រាក់ ជាពលកម្ម ឬដីការប្រជុំជាចំហរមួយ នឹងត្រូវបានធ្វើឡើង ដើម្បីបង្ហាញ និងពិភាក្សាលើការរៀបចំទាំងនេះ ។

២៧. ផែនការអភិវឌ្ឍន៍ឃុំ នឹងឆ្លុះបញ្ចាំងលើការពិចារណាពីព្រឹត្តិការពិសេសៗមួយចំនួន ដែលមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់ខ្ពង់រាបលើចំនុចដូចខាងក្រោមនេះ :

ក). គ.ផ.ឃ នឹងពិនិត្យលើផែនទីឡើងវិញ ដើម្បីធ្វើការវាយតំលៃថា តើការយោគយល់គ្នាពីបញ្ហាព្រំដែនរវាងភូមិទាំងឡាយអាចទទួលយកបានដែរឬទេ ។ នៅទីណាដែលមានជំលោះព្រំដែន គណៈកម្មាធិការនេះ ត្រូវធ្វើការចចារស្វែងរកដំណោះស្រាយ ដែលអាចទទួលយកបានប្រកបដោយការយោគយល់គ្នាមុនពេលជ្រើសរើសសកម្មភាពគំរោងណាមួយ ដែលមានផលប៉ះពាល់ដល់កន្លែងដែលមានជំលោះនោះ ។

ខ). គ.ផ.ឃ នឹងធ្វើការវាយតំលៃថា តើសកម្មភាពគំរោងស្នើឡើង ដែលផ្តល់ផលប្រយោជន៍ដល់តំបន់មួយក្នុងឃុំ អាចមានផលប៉ះពាល់ជាអវិជ្ជមានដល់ភូមិផ្សេងៗ ទៀតដែលនៅក្បែរនោះដែរឬទេ ។

នៅក្នុងឃុំដែលមានភូមិរបស់ប្រជាពលរដ្ឋតំបន់ខ្ពង់រាបរស់នៅ ការវាយតំលៃនេះ នឹងរួមបញ្ចូលទ្ធផលជាបច្ច័យមួយចំនួនដែលអាចកើតមានឡើង ជាពិសេសថាតើការគូសផែនទី និងសិទ្ធិកាន់កាប់ដីបានច្បាស់លាស់គ្រាប់គ្រាន់ហើយឬនៅ ដើម្បីការពារពួកគេមិនអោយផ្លាស់ទីលំនៅចុះឡើងៗក្នុងតំបន់តែមួយ ឬក៏ការពារពួកគេអោយអាចប្រើធនធានដែលមានបាន ។

គ). បញ្ជីតំរូវការជាអាទិភាពរបស់ភូមិ គឺជាប្រភពសកម្មភាពដ៏សំខាន់ សំរាប់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំ ។ បើសិនជាចុងបញ្ចប់ ក្រុមប្រឹក្សាឃុំជ្រើសរើសសកម្មភាពណាមួយ ដែលមិនមាននៅក្នុងបញ្ជីអាទិភាពរបស់ភូមិ ដើម្បីផ្តល់ហិរញ្ញវត្ថុនោះ ការពិគ្រោះយោបល់បន្ថែមទៀត ត្រូវតែធ្វើឡើងនៅថ្នាក់ភូមិ ដើម្បីវាយតំលៃឆន្ទៈចូលរួមរបស់ភូមិ ។

***RILG** នឹងមិនផ្តល់មូលនិធិដល់សកម្មភាពណាមួយ ដែលប៉ះពាល់ដល់ពលរដ្ឋតំបន់ខ្ពង់រាប ដោយគ្មានការយល់ព្រមរបស់ពួកគេ ដូចដែលបានបកស្រាយនៅក្នុងការប្រជុំសំរបសំរួលថ្នាក់ភូមិ ។*

ឃ). ក្នុងឃុំដែលមានអំបូរជនជាតិនៅលាយឡំគ្នា អាទិភាពទាំងឡាយដែលបានលើកឡើងដោយភូមិដែលមានពលរដ្ឋតំបន់ខ្ពង់រាបរស់នៅ អាចមានការប្រគួតប្រជែងជាមួយអាទិភាពផ្សេងៗទៀត ដែលបានលើកឡើងដោយជនជាតិខ្មែរ ឬដែលបានលើកឡើងដោយភូមិផ្សេងៗទៀត ។ ដោយសារគំរោង **RILGP** ជួយជំរុញការកសាងផែនការសមាហរណកម្មអភិវឌ្ឍន៍ឃុំ វាមិនសមស្របក្នុងការបង្កើតអោយមានការពេញចិត្ត សំរាប់ជនជាតិដើមភាគតិច ឬក៏ល័ក្ខខ័ណ្ឌសមស្របសំរាប់ការវិនិយោគ ។ បែបបទនៃការដកភូមិរបស់ពលរដ្ឋតំបន់ខ្ពង់រាប មិនអោយទទួលប្រយោជន៍ពីគំរោង **RILGP** នោះក៏មិនសមស្របដែរ ។

នៅក្នុងករណីដែលផែនការអភិវឌ្ឍន៍ឃុំ មិនបានឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពដែលបានលើកឡើងដោយភូមិដែលមានប្រជាពលរដ្ឋខ្ពង់រាបរស់នៅ ក្រុមប្រឹក្សាឃុំ នឹងប្រើប្រាស់ផែនការ

ហិរញ្ញប្បទាន៣ឆ្នាំ ដែលដកចេញពីផែនការ៥ឆ្នាំ ដើម្បីបង្កើតឆន្ទៈអោយបានជាក់លាក់ ថាតើនៅពេលណា អំពីអ្វីខ្លះដែលអាទិភាពរបស់ភូមិ នឹងត្រូវបានឆ្លើយតប ។

ការចាត់ចែងសំរាប់ការតាមដានត្រួតពិនិត្យ

២៨. ក្នុងគំរោង **RILGP** ការទទួលខុសត្រូវក្នុងការតាមដានគំរោង គឺត្រូវបានបែងចែកក្នុងចំណោមអាជ្ញាធរជាតិ អាជ្ញាធរខេត្តក្រុង និងអាជ្ញាធរឃុំ ។ ក្រុមអ្នកសំរបសំរួលស្រុក ត្រូវទទួលខុសត្រូវជាចំបងលើការតាមដានសកម្មភាពចូលរួមនៅថ្នាក់ភូមិ ។ ចំពោះសកម្មភាពភាគច្រើន ការតាមដាន រួមមានការកត់ត្រាចំនួនអ្នកចូលរួម និងកំណត់ហេតុផ្សេងៗលើទំរង់ការ ។ ឱកាសក៏ត្រូវបានផ្តល់ផងដែរ សំរាប់ការតាមដានតាមបែបចូលរួម នៅថ្នាក់ភូមិ ក្នុងកំឡុងពេលនៃការអនុវត្តគំរោង ។ នៅរៀងរាល់ឆ្នាំ ក្រុមប្រឹក្សាឃុំ នឹងផ្សព្វផ្សាយរបាយការណ៍មួយស្តីពីស្ថានភាពនៃការអនុវត្តកម្មវិធី ។ ភូមិនីមួយៗ អាចពិនិត្យមើលរបាយការណ៍នេះ ដើម្បីធ្វើការកែតំរូវជាទូទៅ ។ បន្ថែមលើនេះទៅទៀត ជារៀងរាល់ឆ្នាំ ប្រធានភូមិនីមួយៗ នឹងពិនិត្យមើលសកម្មភាពគំរោង នៅក្នុងកំរិតនៃការទទួលខុសត្រូវរបស់ខ្លួន ដើម្បីបញ្ជាក់ថាតើការសាងសង់ ការរៀបចំធ្វើកិច្ចសន្យា និងទិដ្ឋភាពផ្សេងៗទៀត ត្រូវបានអនុវត្តសមស្របដែរឬទេ ។

នីតិវិធីក្នុងការដោះស្រាយទំនាស់

២៩. ជាទូទៅ ប្រជាពលរដ្ឋតំបន់ខ្ពង់រាបច្រើនតែ ដឹកនាំ និងចាត់ចែងដោះស្រាយទំនាស់ដែលកើតមានឡើងនៅក្នុងភូមិតាមទំនៀមទំលាប់ប្រពៃណីរបស់ខ្លួន ។ គំរោង **RILGP** បានមើលឃើញថា ការរៀបចំទាំងនេះ គឺជាវិធីសាស្ត្រមួយដ៏សមស្របបំផុត សំរាប់ដោះស្រាយទំនាស់ដំបូងដែលបានកើតឡើងទាក់ទងទៅនឹងគំរោង ។ ក្នុងករណីដែលទំនាស់ណាមួយ មិនអាចធ្វើការដោះស្រាយបាននៅត្រឹមថ្នាក់នេះ ក្រុមអ្នកសំរបសំរួលស្រុក អាចផ្តល់ការសំរុះសំរួលបន្ថែមទៀត ។ បើសិនជាការសំរុះសំរួលមិនបានជោគជ័យ រាល់ទំនាស់ទាំងឡាយទាក់ទងទៅនឹងការរៀបចំផែនការអភិវឌ្ឍន៍ឃុំ នឹងត្រូវបានដោះស្រាយដោយក្រុមប្រឹក្សាឃុំ មុនពេលផែនការត្រូវបានអនុម័ត ។ ទំនាស់ដែលកើតឡើងក្នុងកំឡុងពេលអនុវត្តន៍គំរោង នឹងត្រូវបានដោះស្រាយដោយក្រុមប្រឹក្សាឃុំ មុនពេលដាក់ជូនរបាយការណ៍អនុវត្តន៍ប្រចាំឆ្នាំរបស់ខ្លួនទៅថ្នាក់លើ ។